បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២៧៥០ រៀល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៧ លេខ ២៥ ថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ១៩៩៩

# រាជកិច្ច

**រួមមាន :**

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្តាហ៍

[illegible]

[illegible]

* * *

[illegible]

# [illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]
[illegible]

[illegible]

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រឹត្យ


០១-៧-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៧៩៩/១៤០ លើកលែងទោសអោយជនទណ្ឌិត ១១៦៥

០៥-៧-១៩៩៩ -ព្រះរាជក្រឹត្យ នស/រកត/០៧៩៩/១៤៣ តែងតាំងលោក ហាន់ ឃាង ជាឧកញ៉ា ១១៦៦

០៥-៧-១៩៩៩ -ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/០៥ តែងតាំងឯកឧត្តម ជា សុខុម ជាទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ១១៦៧

០៥-៧-១៩៩៩ -ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/០៦ តែងតាំងឯកឧត្តម កៅ ខុនតារា ជាទីប្រឹក្សាឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ១១៦៨

០៥-៧-១៩៩៩ -ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/០៨ តែងតាំងលោក ខួវ គឹមបាក់ ជាឧកញ៉ា ១១៦៩

០៧-៧-១៩៩៩ -ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/១០ តែងតាំងឯកឧត្តម ឯក វ៉ាន់សារ៉ាត ជាទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ១១៦៩

០៧-៧-១៩៩៩ -ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/១១ តែងតាំងឯកឧត្តម កែម គុណអ៊ិន ជាទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ១១៧០

០៧-៧-១៩៩៩ -ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/១២ តែងតាំងឯកឧត្តម ញ៉ែម វ៉ាលី ជាទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ១១៧១

០៧-៧-១៩៩៩ -ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/១៣ តែងតាំងឯកឧត្តម ជា តាន ជាទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ១១៧២

០៧-៧-១៩៩៩ -ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/១៤ តែងតាំងលោកជំទាវ រស់ គេរី ជាទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ១១៧៣

០២-៧-១៩៩៩ -អនុក្រឹត្យ លេខ ៥១៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១១៧៤

០៥-៧-១៩៩៩ -អនុក្រឹត្យ លេខ ៥១៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១១៧៥

០៥-៧-១៩៩៩ -អនុក្រឹត្យ លេខ ៤១៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១១៧៦

០៦-៧-១៩៩៩ -អនុក្រឹត្យ លេខ ៤១៨ អនក្រ.តត ស្តីពីការអោយចូលនិវត្តន៍មន្ត្រីរាជការ ១១៧៦

០៧-៧-១៩៩៩ -អនុក្រឹត្យ លេខ ៤១៩ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១១៧៨

០៧-៧-១៩៩៩ -អនុក្រឹត្យ លេខ ៤២០ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ១១៧៩

០៨-៧-១៩៩៩ -អនុក្រឹត្យ លេខ ៤២១ អនក្រ.តត ស្តីពីការតែងតាំងរដ្ឋមន្ត្រីសេដ្ឋកិច្ចកម្ពុជា សំរាប់អាស៊ាន ១១៧៩

## ២-សេចក្តីសំរេច

០២-៧-១៩៩៩ -សេចក្តីសំរេច លេខ ៥០ សសរ ស្តីពីការលុបចោលរោងចក្រអារឈើ និងរោងម៉ាស៊ីនអារឈើ នៅទូទាំងប្រទេស ១១៨១

០៨-៧-១៩៩៩ -សេចក្តីសំរេច លេខ ៥១ សសរ ស្តីពីការផ្ទេរសិទ្ធិរដ្ឋមន្ត្រី ១១៨៣

# III- ការងារបណ្តាក្រសួង

## ១-នីស្តីការរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### ១-ប្រកាសណែនាំ

០៥-៧-១៩៩៩ -ប្រកាសណែនាំលេខ ៤៨៩ ប្រក.សហវ.ថ ស្តីពី នីតិវិធីបច្ចេកទេស នៃការរៀបចំគំរោងថវិការបស់ខេត្ត ក្រុង ឆ្នាំ ២០០០ ១១៨៤

### ២-សារាចរណែនាំ

០៥-៧-១៩៩៩ - សារាចរណែនាំលេខ ០១១ សហវ.ថ ស្តីពី បច្ចេកទេសនៃការរៀបចំគំរោងថវិកា ឆ្នាំ ២០០០ ១១៩៥

## ២-នីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

### ប្រកាស

០២-៧-១៩៩៩ -ប្រកាសលេខ ៦៥៨ ផក-ប្រក អនុញ្ញាតអោយក្រុមហ៊ុន អូសេអង់ហ្គាមិន (OCEAN GARMENT COl.LTD ) តំណាងដោយលោក CABDUL MANNAN សញ្ជាតិបង់ក្លាដេស បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ ១២២០

០២-៧-១៩៩៩ -ប្រកាសលេខ ០៦២៦/៩៩ ពម-ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការនៅមន្ទីរ ពត៌មានខេត្តបន្ទាយមានជ័យ ១២២១

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១-ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៧៩៩/១៤០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី ២០-៦-៩៩

ទ្រង់ត្រាស់បង្គាប់

មាត្រា ១ .- ត្រូវលើកលែងទោសអោយទណ្ឌិតចំនួន ៨ រូប ដែលវិជ្ជាស្ថានប៉ាស្ទ័រ បានបញ្ជាក់ថា មានផ្ទុកមេរោគ HIV (AIDS ) ដូចមានរាយឈ្មោះខាងក្រោមនេះ ៖

១-ទណ្ឌិតឈ្មោះ ស៊ុយ វ៉ាយ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១ឆ្នាំ ៦ខែ តាមអំណាចសាលក្រមលេខ ៧០ ចុះថ្ងៃទី ៧-៩-៩៨ របស់តុលាការខេត្តកំពង់ធំ ។

២-ទណ្ឌិតឈ្មោះ ស្វាយ ឆាន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ ចុះថ្ងៃទី ២៥-៨-៩៧ របស់តុលាការក្រុងព្រះសីហនុ ។

៣-ទណ្ឌិតឈ្មោះ សំ នូ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាច សាលក្រមលេខ ២៣ ចុះថ្ងៃទី ២៥-៨-៩៧ របស់តុលាការក្រុងព្រះសីហនុ ។

៤-ទណ្ឌិតឈ្មោះ នែម ផុន ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ ចុះថ្ងៃទី ២៥-៨-៩៧ របស់តុលាការក្រុងព្រះសីហនុ ។

៥-ទណ្ឌិតឈ្មោះ ថៃ ធុល ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាច សាលក្រមលេខ ០៧ ចុះថ្ងៃទី ០២-២-៩៨ របស់តុលាការខេត្តព្រៃវែង ។

៦-ទណ្ឌិតឈ្មោះ សុះ ការសម ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១៥ឆ្នាំ តាមអំណាច សាលក្រមលេខ ៥៩ "ខ" ចុះថ្ងៃទី ៩-៩-៩៧ របស់តុលាការក្រុងភ្នំពេញ ។

៧-ទណ្ឌិតឈ្មោះ ថ្រុំ មាននិទ្ធិ ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ឆ្នាំ តាមអំណាច ដាលក្រមលេខ ៥៤"ខ" ចុះថ្ងៃទី ៩-៩-៩៧ របស់តុលាការក្រុងភ្នំពេញ ។

៨-ទណ្ឌិតឈ្មោះ ម៉ិន បញ្ញាធី ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់១០ឆ្នាំ តាមអំណាច ដាលក្រមលេខ ១៣"ខ" ចុះថ្ងៃទី ២៨-៦-៩៨ របស់តុលាការក្រុងភ្នំពេញ ។

**មាត្រា ២ .-** ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

**មាត្រា ៣ .-** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះអោយបានសំរេចជាស្ថាពរ ។

ធ្វើនៅថ្ងៃទី០១ ខែ កក្កដា ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

**នរោត្តម សីហនុ**

***

ព្រះរាជក្រឹត្យ នស/រកត/០៧៩៩/១៤៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

* * *

# តែងតាំង

# លោក ហាន់ ឃាង

# ជា

# ឧកញ៉ា

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

នរោត្តម សីហនុ

***

# ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/០៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់ឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់ឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់ឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៩

ត្រាស់បង្គាប់

**មាត្រា ១ .-** តែងតាំងឯកឧត្តម ជា សុខុម ជាទីប្រឹក្សា ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកការងារពិធីការ មានឋានៈស្មើ អគ្គនាយក ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែ កក្កដា ឆ្នាំ ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

# ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/០៦

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៩

**ត្រាស់បង្គាប់**

មាត្រា ១ .- តែងតាំងឯកឧត្តម កៅ ខុនតារា ជាទីប្រឹក្សា ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកការងារសេដ្ឋកិច្ច មានឋានៈស្មើ អគ្គនាយក ។

មាត្រា ២ .- បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ .- នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានច្បាប់ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៥ ខែ កក្កដា ឆ្នាំ ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/០៨

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

* * *

# តែងតាំង

# លោក ខុច គឹមបាក់

# ជា

# ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/១០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៩

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និង មាត្រាទាំងឡាយ នៃជំពូក ទី៨

ដល់ ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/ ០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា

-យោងតាមសំណូមពរចាំបាច់នៃការងារ

## ត្រាស់បង្គាប់

**មាត្រា ១ .-** តែងតាំងឯកឧត្តម **ឯល ទ៉ាន់សាំរិត** ជាទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារយោធា មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា ២ .-** ប្រធានព្រឹទ្ធសភា និង នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ

**មាត្រា ៣ ._** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ,ធ្វើនៅថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

## ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/១១

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

-បានទ្រង់ទតរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និង មាត្រាទាំងឡាយ នៃជំពូក ទី៨ ដល់ ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/ ០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា

-យោងតាមសំណូមពរចាំបាច់នៃការងារ

**ត្រាស់បង្គាប់**

**មាត្រា ១ .-** តែងតាំងឯកឧត្តម ហែម សាមិន ជាទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារទំនាក់ទំនងជាមួយខេត្ត-ក្រុង មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២ .-** ប្រធានព្រឹទ្ធសភា និង នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ

**មាត្រា ៣ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

***

## ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/១២

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និង មាត្រាទាំងឡាយ នៃជំពូក ទី៨ ដល់ ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/ ០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា

-យោងតាមសំណូមពរចាំបាច់នៃការងារ

ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំងឯកឧត្តម ស្វៀម ទាំលី ជាទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារទំនាក់ទំនងមហាជន បណ្តាសមាគម និងអង្គការក្រសួង មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ .- ប្រធានព្រឹទ្ធសភា និង នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ ១៩៩៩

ក្នុងព្រះបរមនាម និងតាមព្រះរាជព្រាត់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/១៣

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលព្រះរាជកត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និង មាត្រាទាំងឡាយ នៃជំពូក ទី៨ ដល់ ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/ ០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា

-យោងតាមសំណូមពរចាំបាច់នៃការងារ

## ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំងឯកឧត្តម ជា គាន ជាទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារពុទ្ធសាសនា ពាហិរសាសនា និងការងារនិពន្ធ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ .- ប្រធានព្រឹទ្ធសភា និង នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ មានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ ១៩៩៩
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា
ជា ស៊ីម

***

## ព្រះរាជក្រឹត្យ ជស/រកត/០៧៩៩/១៤

### យើង

### ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
### រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
### និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
### ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់ធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និង មាត្រាទាំងឡាយ នៃជំពូក ទី៨ ដល់ ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/ ០៣៩៩/៥៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា

-យោងតាមសំណូមពរចាំបាច់នៃការងារ

ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំងលោកជំទាវ រស់ សេរី ជាទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារកិច្ចការនារី មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ .- ប្រធានព្រឹទ្ធសភា និង នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ ១៩៩៩
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា
ជា ស៊ីម

***

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យ លេខ ៤១៥ អនក្រ.តត
### ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា ១ .- តែងតាំងលោក សោខ វិចណ្ណៈ អតីតអនុរដ្ឋលេខាធិការ នៃក្រសួងផែនការ ជាអគ្គទីប្រឹក្សាស្ថានទូត នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យ លេខ ៨១៦ អនក្រ .តត
## ស្ដីពីការតែងតាំងមន្ត្រីរាជការ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ .-** តែងតាំងលោក **ឃុន កុមារ** បច្ចុប្បន្ន អនុប្រធាននាយកដ្ឋាន ទទួលបន្ទុកផ្នែកសហប្រតិបត្តិការសន្តិសុខនៃអគ្គនាយកដ្ឋាន អាស៊ាន ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានអាស៊ាន ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្ត អនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

## អនុក្រឹត្យ លេខ ៤១៧ អនក្រ .តត
## ស្ដីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១.-** តែងតាំងលោក **ណៃ ម៉េងអ៊ាង** បច្ចុប្បន្នលេខាធិការទី១ នៃស្ថានបេសកកម្មអចិន្ត្រៃយ៍ ជាទីប្រឹក្សាស្ថានបេសកកម្មអចិន្ត្រៃយ៍ នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យ នេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យ លេខ ៤១៨ អនក្រ .តត
## ស្ដីពីការអោយចូលនិវត្តន៍មន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការ នៃព្រះរាជាណាចក្រកម្ពុជា

-យោង សារាចរលេខ០៤ សរ ចុះថ្ងៃទី១៧ ខែ មីនា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាល

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សំរេច

មាត្រា ១ .- ត្រូវបានអោយថ្នាក់ដឹកនាំ០១រូប និងមន្ត្រីថ្នាក់នាយកដ្ឋានចំនួន ០៧រូប ចូលនិវត្តន៍ ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១-ឯកឧត្តម ឈា ថាំង | អតីតរដ្ឋមន្ត្រី |
| ២-លោក អ៊ុំ សារឹន | នាយកមន្ទីរពេទ្យព្រះកុសុមៈ |
| ៣-លោក នីនយុសុះ អាប់ឌុលក្ខយ៉ូម | នាយកមជ្ឈមណ្ឌលជាតិកំចាត់ជំងឺគ្រុនចាញ់ |
| ៤-លោក គង់ គឹមសាន | នាយកមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង ហង់សិន |
| ៥-លោក លុន គឹមឆាង | ព្រឹទ្ធបុរសមហាវិទ្យាល័យឱសថសាស្ត្រ |
| ៦-លោក ថៃ ហ្វា | សាកលវិទ្យាធិការរង |
| ៧-លោក តាំង ម៉ុនលីម | ព្រឹទ្ធបុរសមហាវិទ្យាល័យវេជ្ជសាស្ត្រ |
| ៨-លោក ហ៊ុយ សេដ្ឋ | ប្រធាននាយកដ្ឋានរដ្ឋបាល |

មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ៤១៩ អនក្រ .តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ២០/អនក្រ/បក/ ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

-យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សំរេច

**មាត្រា ១ .-** ត្រូវបានតែងតាំងអស់លោក ជាទីប្រឹក្សាឯកឧត្តម **ស ខេង** សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ ប្រធាននាយកដ្ឋាន ដូចមានរាយនាមខាងក្រោម ៖

១-លោក **រស់ វរុណ**

២-លោក **សុខ សេរីវុធ**

៣-លោក **ស៊ុយ សេរីវឌ្ឍ**

**មាត្រា ២.-** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

## អនុក្រឹត្យ លេខ ៤២០ អនក្រ .តត
## ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ .-** ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ វរសេនីយ៍ឯក ជូនលោក **ថោង ទិវលក្ខណ៍** ជំនួយការឯកឧត្តម **ហុក ឡុងឌី** អគ្គនាយកនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យ លេខ ៤២១ អនក្រ .តត
## ស្តីពីការ តែងតាំង រដ្ឋមន្ត្រីសេដ្ឋកិច្ចកម្ពុជាសំរាប់អាស៊ាន

***

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

-បានឃើញអនុក្រឹត្យ លេខ ៣២ អនក្រ.បក ចុះថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ ១៩៩៦ ស្តីពីការចាត់តាំង និងការប្រព្រឹត្តទៅ នៃប្រព័ន្ធសំរបសំរួលផ្ទៃក្នុង (ICN)

-យោងតាមសំណូមពរការចាំបាច់នៃការងារ

## សំរេច

**មាត្រា ១ .-** តែងតាំងឯកឧត្តមរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ជារដ្ឋមន្ត្រីសេដ្ឋកិច្ចកម្ពុជា សំរាប់អាស៊ាន ។

**មាត្រា ២ .-** រដ្ឋមន្ត្រីសេដ្ឋកិច្ចកម្ពុជាសំរាប់អាស៊ាន មានភារកិច្ចដូចតទៅ :

ក-ទទួលខុសត្រូវក្នុងការសំរបសំរួល និងការដឹកនាំសហប្រតិបត្តិការសេដ្ឋកិច្ចកម្ពុជា ជាមួយប្រទេសសមាជិកអាស៊ាន ដទៃទៀត ។

ខ-ចូលរួមក្នុងរាល់កិច្ចប្រជុំ នៃរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ( ASEAN Economic Ministers “ AEM ” ) ។

គ-ត្រួតពិនិត្យ តាមដាន និងគាំទ្រ រាល់ការអនុវត្តន៍កិច្ចព្រមព្រៀងសេដ្ឋកិច្ចអាស៊ាន ។

**មាត្រា ៣.-** រដ្ឋមន្ត្រីសេដ្ឋកិច្ចកម្ពុជាសំរាប់អាស៊ាន មានសិទ្ធិអញ្ជើញ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងមន្ត្រីជំនាញ នៃក្រសួង និង ស្ថាប័នពាក់ព័ន្ធនានា មកចូលរួមប្រជុំ ដើម្បីពិភាក្សា និងដោះស្រាយបញ្ហាការងារផ្សេងៗ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ាន និងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន ។

**មាត្រា ៤.-** រដ្ឋមន្ត្រីសេដ្ឋកិច្ចកម្ពុជាសំរាប់អាស៊ាន ត្រូវរាយការណ៍ជាប្រចាំអំពីការងាររបស់ខ្លួន និងលទ្ធផលនៃកិច្ចប្រជុំនានា ដូចមានចែងក្នុងមាត្រា២ មកនាយករដ្ឋមន្ត្រី ដែលជាប្រធានប្រព័ន្ធសំរបសំរួលផ្ទៃក្នុង (ICN) ។

**មាត្រា ៥.-** រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានពីមុនមក ហើយផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៦.-** ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ក្រសួង និងស្ថាប័នសាមីពាក់ព័ន្ធ និងគណៈកម្មការត្រូវអនុវត្ត អនុក្រឹត្យនេះ ដោយមានប្រសិទ្ធភាព ចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## ២-សេចក្តីសំរេច

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៩

**សេចក្តីសំរេចលេខ ៥០ សសរ**

**ស្តីពីការលុបចោលរោងចក្រអារឈើ និងរោងម៉ាស៊ីន**

**អារឈើ នៅទូទាំងប្រទេស**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញក្រឹត្យ-ច្បាប់ លេខ ៣៥ ក្រច. ចុះថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការគ្រប់គ្រង វិស័យព្រៃឈើ

-បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ០១ ប្រក ចុះថ្ងៃទី២៥ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីវិធានការគ្រប់គ្រង និងលុបបំបាត់ ភាពអនាធិបតេយ្យវិស័យព្រៃឈើ

-យោងតាមសំណូមពរអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៩

**សំរេច**

**ប្រការ ១ :** លុបចោលនូវរាល់ការអនុញ្ញាតឱ្យប្រកបអាជីវកម្មព្រៃឈើ និងរោងម៉ាស៊ីនអារឈើ ដែលក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ស្ថាប័ន និងអាជ្ញាធរដែនដី បានអនុញ្ញាតកន្លងមក ។

ប្រការ ២ : អនុញ្ញាតអោយបន្តសុពលភាពប្រកបអាជីវកម្មរោងចក្រអារឈើ ផលិតគ្រឿងផ្ទះ និងកែច្នៃឈើរបស់ក្រុមហ៊ុនចំរុះរដ្ឋ ឬ របស់ក្រុមហ៊ុនវិនិយោគទុនដែលមានព្រៃសម្បទានស្របច្បាប់ ដោយត្រូវបំពាក់បន្ថែមមធ្យោបាយកែច្នៃទំនើប ដើម្បីបង្កើនតម្លៃបន្ថែមនៃឈើ និងបង្កើនការងារជូនប្រជាពលរដ្ឋ ។

ប្រការ ៣ : ចំពោះសហគ្រាសវិនិយោគរោងចក្រ រោងសិប្បកម្មកែច្នៃផលិតគ្រឿងសង្ហារិម និងវត្ថុសិល្បៈអំពីឈើ និងអនុផលព្រៃឈើសំរាប់បំរើការនាំចេញ និងការប្រើប្រាស់ចាំបាច់ក្នុងប្រទេស និងដេប៉ូលក់ឈើ ត្រូវបានរក្សាទុកអោយបន្តធ្វើអាជីវកម្មលើមូលដ្ឋានមានកិច្ចសន្យាច្បាស់លាស់ ពីភាគីផ្គត់ផ្គង់ឈើ ដោយអនុលោមតាមផែនការដកហូតឈើសំរាប់ធ្វើអាជីវកម្មប្រចាំឆ្នាំរបស់ក្រុមហ៊ុនព្រៃសម្បទានស្របច្បាប់ ដែលកំណត់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

ប្រការ ៤ : រាល់អាជីវកម្មរបស់រោងចក្រ រោងម៉ាស៊ីនអារឈើ ដែលមិនផ្សារភ្ជាប់នឹងក្រុមហ៊ុនព្រៃសម្បទានស្របច្បាប់ ត្រូវហាមឃាត់ជាដាច់ខាត ។

ប្រការ ៥ : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវតាមដានត្រួតពិនិត្យអោយបានត្រឹមត្រូវចំពោះការលក់ឈើក្នុងអត្រាអតិបរមា ២០ % នៃផលិតផលឈើប្រចាំឆ្នាំរបស់ក្រុមហ៊ុនព្រៃសម្បទាន សំរាប់បំរើដល់ការផ្គត់ផ្គង់ឈើនៅក្នុងប្រទេស ។

ប្រការ ៦ : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចគ្រប់គ្រងដេប៉ូលក់ឈើ និងអនុផលព្រៃឈើទូទាំងប្រទេស តាមរយៈការត្រួតពិនិត្យ និងការកំណត់បរិមាណផ្គត់ផ្គង់ និងគន្ធិឈើ និងអនុផលព្រៃឈើ នៅតាមដេប៉ូលក់ឈើនីមួយៗ ព្រមទាំងការត្រួតពិនិត្យអោយដេប៉ូឈើទាំងអស់លក់ឈើ ឬ អនុផលព្រៃឈើដែលមានប្រភពស្របច្បាប់ ចេញពីព្រៃសម្បទាន ។

ប្រការ ៧ : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចធ្វើសភាពការណ៍រាយការណ៍លំអិតអំពីការអនុវត្តន៍សេចក្តីសំរេចនេះ ។

ប្រការ ៨ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៩ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រី រដ្ឋលេខាធិការដ្ឋាន គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលគ្រប់ខេត្ត-ក្រុង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ១៩៩៩

## សេចក្តីសំរេច លេខ ៥១ សសរ

## ស្តីពីការផ្ទេរសិទ្ធិរដ្ឋមន្ត្រី

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-យោងតាមតម្រូវការការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** ផ្ទេរសិទ្ធិជូនឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទទួលបន្ទុកបន្ថែមជារដ្ឋមន្ត្រី នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជំនួសឯកឧត្តម **ហោ ណាំហុង** ដែលត្រូវបានអញ្ជើញទៅបំពេញបេសកកម្មនៅក្រៅប្រទេស ចាប់ពីថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ ១៩៩៩ រហូតដល់ថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៩ ។

**ប្រការ ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នប្រតិភូរាជរដ្ឋាភិបាល អភិបាលខេត្ត-ក្រុង និង ឯកឧត្តម **គាត ឈន់** ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

# III- ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## ១-ប្រកាសណែនាំ

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ ១៩៩៩

### ប្រកាសណែនាំ លេខ ៤៨៩ ប្រក. សហវ.ថ
### ស្តីពី នីតិវិធី បច្ចេកទេសនៃការរៀបចំគំរោងថវិកា
### របស់ខេត្ត ក្រុងឆ្នាំ ២០០០

***

យោងប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពីរបប បញ្ចេញថវិកា របស់ខេត្ត-ក្រុង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំ ស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគំរោងថវិកា របស់ខេត្ត-ក្រុង ឆ្នាំ ២០០០ ដូចតទៅ ៖

**I-ការរៀបចំចំណូលថវិកា :**

១-ការគិតគូរចំណូលជាប្រចាំនៃថវិការបស់ខេត្ត ក្រុង អាស្រ័យទៅលើប្រភពនៃចំណូលជាក់ស្តែង ឬ ចំណូលមុន ដូចមាន ចែងក្នុងមាត្រា ១៧ នៃច្បាប់ ស្តីពីរបបហិរញ្ញវត្ថុ និង ទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ។

ផ្អែកតាមប្រភពចំណូលខាងលើនេះ អភិបាលខេត្ត-ក្រុង ត្រូវរៀបចំនូវគំរោងចំណូលរបស់ខ្លួន ដូចតទៅ ៖

-ចំណូលសារពើពន្ធ ត្រូវគិតគូរដោយផ្អែកលើមូលដ្ឋានដូចខាងក្រោម ៖

+ លទ្ធផលដែលទទួលបាននៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅ
+ អានុភាពនៃអតិផរណាមកលើមូលដ្ឋានពន្ធ
+ ប៉ាន់ស្មានលើការវិវត្តន៍សេដ្ឋកិច្ចនៅពេលខាងមុខ
+ ការកែប្រែប្រួលដែលអាចកើតមានឡើង ឬត្រូវពិនិត្យពិចារណាលើអត្រា និង មូលដ្ឋានប្រមូលពន្ធ
+ ចំណូលដែលរំពឹងថាបានមកពីការបង្កើតពន្ធថ្មី ។

-ទន្ទឹមនឹងនោះ ចំណូលពុំមែនសារពើពន្ធ ត្រូវបានគិតគូរទៅតាមកិច្ចការដែលនាំអោយមានចំណូលទុន ដូចជាកិច្ចសន្យាជួល សេវាកម្ម... ។ ចំណូលទាំងអស់នេះ ត្រូវផ្អែកលើមូលដ្ឋានតួលេខស្ថិតិសំរេចបាន នៃឆ្នាំកន្លងមក និងការវិវឌ្ឍន៍នៃសេដ្ឋកិច្ច ។

ចំពោះនីតិវិធី គឺអភិបាលខេត្ត-ក្រុង (ក្រុមហិរញ្ញវត្ថុ) ត្រូវអញ្ជើញមន្ត្រីសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ គណនេយ្យករ និង មន្ត្រីជំនាញដែលពាក់ព័ន្ធ ក្នុងការប្រជុំរៀបចំគម្រោងគោលការណ៍ និងកុំម៉ង់គោលការណ៍ ចំណាយថវិកាខេត្ត-ក្រុង ដើម្បីពិនិត្យរៀបចំចំណាត់ថ្នាក់ចំណូលគម្រោង ទៅតាមតារាងគំរូលេខ១ ដែលភ្ជាប់មកជាមួយនេះ ។

២-ចំណូលដែលក្នុងការប្រមូលពន្ធនៃថវិការបស់ខេត្ត-ក្រុង នោះបើពុំប្រមូលមិនបានអនុវត្តត្រឹមត្រូវ តាមដែលបានគោលការណ៍អនុញ្ញាតពីរាជការ ក្នុងករណីដែលមាន គឺត្រូវរកកត្តាមូលហេតុដែលបណ្តាលទៅក្នុងចំណាត់ចំណូលមន្ត្រីនោះក៏ត្រូវរកកត្តាមូលហេតុដែលត្រូវបញ្ចូលរដ្ឋចំណូលពីជំនួយអន្តរជាតិ និងជំនួយបរទេសដែលគេប្រគល់ឱ្យ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា បានទៅផ្គត់ផ្គង់ផ្ទាល់ជាមួយខេត្ត ក្រុងរួចហើយនោះ ។

## II-ការរៀបចំចំណាយថវិកា :

៣-ខេត្ត-ក្រុងត្រូវរៀបចំផ្នែកចំណាយចំណោកការចាំបាច់ទាំងអស់ ស្ថិតនៅក្រោមឱវាទរបស់អ្នកដែលមានសមត្ថភាព ។ សម្រាប់ពិនិត្យផ្លូវចំណាយការទាំងឡាយ គឺជាការចំណាយផ្លូវមុខចំណាយនីមួយៗ ដោយផ្ទាល់ការ និងដោយផ្នែកទៅលើកត្តាកេតា ដែលទាក់ទងផ្ទាល់ទៅនឹងមុខចំណាយនោះ មានដូចជាតារាងបុគ្គលិក បញ្ជីទ្រព្យសម្បត្តិ តម្លៃសម្ភារៈ ប្រភេទ ការជួសជុល .... ។ ចំពោះសម្ភារកម្មមួយចំនួន ពោលទារដោយមានបញ្ជីលម្អិតការ សម្រាប់ផ្គត់ផ្គង់ ចំណាយបញ្ជូនក្នុងមួយម៉ែត្រការេ ចំណុះទឹកចាំបាច់សម្រាប់ធ្វើក្រឡាពេលប្រើការប្រើប្រាស់ម៉ាស៊ីនភ្លើង គិតជាម៉ោងតម្លៃ ការលើការចំណែកប្រេងឥន្ធនៈ គិតតាមគីឡូម៉ែត្រ .... ។ ក៏ប៉ុន្តែចំពោះសម្ភារៈបរិក្ខារដែលប្រើប្រាស់ជាប្រចាំ ត្រូវពិចារណាដោយផ្អែកទៅតាមតួលេខ ស្ថិតិលើលទ្ធផលថវិកាជាមធ្យមភាគនៃការអនុវត្តកន្លងមក ។ ចំណែកឯសេវាកម្មប្រើប្រាស់ផ្សេងៗ ក្នុងនោះ សេវាកម្ម ត្រូវផ្អែកលើបទពិសោធន៍ដែលមានកន្លងមក ។

ចំណាត់ចំណាយទាំងអស់របស់ថវិកាខេត្ត ក្រុង ត្រូវបានសរុបក្នុងតារាងគំរូលេខ២ ដែលភ្ជាប់មកជាមួយនេះ ។

៤-ជាមួយនេះ ស្នើចំណាយទាំងអស់សម្រាប់ការគ្រប់គ្រង ត្រូវតែមានការវិភាគ និងមានហេតុផលត្រឹមត្រូវភ្ជាប់មកជាមួយ តាមចំពូក តាមប្រការ ដើម្បីបង្ហាញភាពចាំបាច់ ការពិតរបស់ចំណាយរបស់ខ្លួនមានលក្ខណៈត្រឹមត្រូវច្បាស់លាស់ និងសមហេតុផល ។ ហេតុផលត្រូវការទាំងអស់នេះ នឹងធ្វើជាមូលដ្ឋាននៃការពិនិត្យពិភាក្សាថវិកា ។

៥-ប្រភពចំណាយនេះ ក៏មានភ្ជាប់តាមសមាសភាគដែលត្រូវគ្នាចំណុះសម្រាប់ចំណាយផ្លូវឥតពោះ ដែលត្រូវស្នើសុំទៅតាមមុខចំណាយនីមួយៗ ។ សមាសភាគទាំងអស់នេះ ត្រូវបានអង្គភាពនានារបស់ខេត្ត ក្រុង ប្រើប្រាស់សម្រាប់ផ្តល់ប្រាក់ឧបត្ថម្ភ នៅពេលការស្នើសុំដែលបានរបស់ខ្លួន ។

II.1- **គំរោងចំណាយជាប្រចាំ :**

៦-លិខិតបញ្ជាការណ៍នៃការចំណាយជាប្រចាំ មានជាគោលសំខាន់ៗដូចតទៅ ៖

## ប្រភេទ ១ : មធ្យោបាយសេវា

## ជំពូក១០ : ប្រាក់បៀវត្ស និង ប្រាក់ចំណាយ

៧-ចំណាយសំរាប់បុគ្គលិក ត្រូវតែគិតគូរអោយបានច្បាស់លាស់ ។ ពុំមានវិធានការណាមួយនៃចំណាយជំពូកនេះត្រូវបានបណ្តែតទេ បើសិនចំណាយជំពូកនេះមិនបានគ្រោងទុក និងមិនបានអនុញ្ញាតជាមុនដោយថវិកាទេនោះ ។ ការបើកកៅអីថ្មី ឬការតម្លើងកៅអីដែលកំពុងមាន ការបង្កើត និងការកែប្រែឋានន្តរស័ក្តិ និងការជ្រើសរើសបុគ្គលិកបន្ថែម ..... ត្រូវតែទទួលការអនុញ្ញាតអោយកត់ត្រាទុកនៅក្នុងថវិកា ឬវិធានការណ៍ចាំបាច់ជាមុនសិន មុននឹងចាប់ផ្តើមអនុវត្ត ។

**ក-បុគ្គលិកកំពុងមានបច្ចុប្បន្ននេះ**

៨-ចំនួនបុគ្គលិកមន្ត្រីរាជការទាំងអស់ ដែលស្ថិតក្រោមឱវាទខេត្ត-ក្រុង ត្រូវបូកសរុបនៅក្នុងសំណេកប័ត្រ១ ដែលបានជូនភ្ជាប់មកជាមួយនេះ ។ សំណេកប័ត្រនេះមានចែកជាក្រឡាខ្ទង់ សំរាប់កត់ត្រានូវប្រភេទបុគ្គលិកទាំងអស់ដែលខេត្ត-ក្រុងមាន ។

៩-សំណេកប័ត្រ១នេះ គឺជាសរុបបុគ្គលិក មន្ត្រីរាជការ ដែលរាប់គិតទៅតាមអង្គភាពនីមួយៗ ។ ហើយចំនួននេះត្រូវតែស៊ីគ្នាជាមួយនឹងចំនួនដែលមាននៅក្នុងតារាងសរុបចំណាយ ។

១០-ខេត្ត-ក្រុង ត្រូវរាប់គិតចំនួនបុគ្គលិកទៅតាមស្រុក ខ័ណ្ឌនីមួយៗ ដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន។

**ខ-ការជ្រើសរើសបុគ្គលិកថ្មី**

១១-អភិបាលខេត្ត-ក្រុង តែងតាំងបុគ្គលិកខេត្ត ក្រុងក្នុងក្របខ័ណ្ឌថវិការបស់ខេត្ត ក្រុង ទៅតាមការកំណត់នៃលិខិតបទដ្ឋាន ដែលមានចែងជាធរមាន ក្រៅពីច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ហើយបុគ្គលិកទាំងនេះ ត្រូវគោរពតាមតួកិច្ចដែលចុះរួចចំពោះភ្នាក់ងារសាធារណៈទាំងអស់ ។ ខេត្ត-ក្រុងអាចជ្រើសរើសបុគ្គលិកអោយធ្វើការបាន គឺក្រិតបុគ្គលិកប្រភេទ "គ" និង "ឃ" ដែលចាំបាច់បំផុត ក្រោយពីបានប្រើប្រាស់អោយអស់លទ្ធភាពនូវមន្ត្រីរាជការដែលមានស្រាប់ ។ ខាងលើនេះ គឺជាគោលការណ៍រួម ក៏ប៉ុន្តែក្នុងសភាពការណ៍បច្ចុប្បន្ន ដែលរាជរដ្ឋាភិបាលកំពុងអនុវត្តគោលនយោបាយកែទំរង់រដ្ឋបាល និងកាត់បន្ថយក្របខ័ណ្ឌនោះ គឺមិនអនុញ្ញាតអោយខេត្ត ក្រុង ជ្រើសរើសបុគ្គលិកថ្មីទេ ។

## ជំពូក១១ : ដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច

១២-ជំពូក១១ ប្រមូលផ្តុំរាល់ចំណាយសំភារៈ និងចំណាយគ្រប់គ្រងរដ្ឋបាលចាំបាច់សំរាប់ដំណើរការ នៃសេវារបស់ខេត្ត ក្រុង ។ ជំពូកនេះមិនបង្ហាញអោយឃើញពីសេវាទទួលចំណាយដោយផ្ទាល់ទេ ។ ក៏ប៉ុន្តែការធ្វើយុត្តិកម្មលើសំណើសុំឥណទាន ត្រូវតែផ្អែក ទាំងទៅលើប្រភេទចំណាយ ទាំងទៅលើសេវាទទួលចំណាយផង ។

សំណាកប័ត្រយុត្តិការណ៍ ដែលមាននៅខាងក្រោមនេះសំរាប់បង្ហាញនូវខ្ទង់ចំណាយសំខាន់ៗក្នុងជំពូក១១ ទៅតាមអង្គភាពពាក់ព័ន្ធ ។

-អគ្គិសនី (សំណាកប័ត្រ២) : ឥណទានត្រូវបានបែងចែកតាមកន្លែងប្រើប្រាស់នៃអគ្គិសនី ដូចជាប្រើប្រាស់នៅកន្លែងរដ្ឋបាល ឬនៅលំនៅដ្ឋាន និងតាមប្រភេទចំណាយ ដូចជាការថែទាំ ការប្រើប្រាស់ទឹក អគ្គិសនី ។

-ចលនវត្ថុ សំភារៈ (សំណាកប័ត្រ៣) : គប្បីបែងចែកដាច់ពីគ្នា រវាងការទិញ និងថែទាំ ។ មានខ្ទង់មួយដែលត្រូវបំពេញក្នុងសំណាកប័ត្រ គឺសំរាប់សំភារៈការិយាល័យ ។

-រថយន្ត (សំណាកប័ត្រ៤) : ជាទូទៅ រថយន្តគឺជាមុខសញ្ញាប្រើប្រាស់ឥណទានយ៉ាងធំធេង និងត្រូវមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីគ្រប់គ្រងការកើនឡើងចំណាយនេះ ។ ការធ្វើយុត្តិកម្មឥណទាន ត្រូវតែមានភាពច្បាស់លាស់ និងត្រូវផ្អែកទៅលើគុណភាពនៃរថយន្ត ម៉ាករថយន្ត ផ្លាកលេខ ឆ្នាំទិញ ចម្ងាយផ្លូវបើកបរជាគីឡូម៉ែត្រ ។ ដោយហេតុនេះ ឥណទានដែលបានស្នើសុំ ត្រូវបែងចែកសំរាប់ការថែទាំ សំរាប់ប្រេងឥន្ធនៈ និងសំរាប់ប្រេងរំអិល ។ ត្រូវធ្វើការកត់សំគាល់ពិសេសមួយ ទៅលើរថយន្តដែលប្រើប្រាស់ជាលក្ខណៈបុគ្គលដោយមន្ត្រីរាជការ ដាក់លេខរដ្ឋ ហើយប្រើប្រាស់ប្រេងឥន្ធនៈរដ្ឋ ។

- សោហ៊ុយផ្លាស់ប្តូរទីកន្លែង (សំណាកប័ត្រ៥) : គឺជាប្រាក់បំណាច់ផ្លាស់ប្តូរទីកន្លែង សំរាប់មន្ត្រីរាជការបំពេញបេសកកម្ម ។ ប្រការនេះ ក៏ត្រូវតែបែងចែកអោយដាច់ពីគ្នា ទៅតាមការផ្លាស់ប្តូរទីកន្លែងដែលត្រូវធ្វើឡើងនៅក្នុងមណ្ឌល អន្តរមណ្ឌល និងបេសកកម្មក្រៅប្រទេស ។ ការគ្រោងគិតទៅលើសោហ៊ុយបេសកកម្មអោយមានភាពជាក់លាក់ ត្រូវតែផ្អែកលើការផ្លាស់ប្តូរទីកន្លែងដែលត្រូវធ្វើ ចំនួនលើក រយៈពេល ចំនួនបុគ្គលិកដែលពាក់ព័ន្ធ ។

- ចំណាយជាគុណប្រយោជន៍ខេត្ត ក្រុង ដូចជាចំណាយបំភ្លឺសាធារណៈ ការប្រមូលសំរាម ថែទាំផ្លូវថ្នល់ សួនច្បារសាធារណៈ ប្រឡាយ លូទឹក .... ។ ល ។ ត្រូវមានតារាងលំអិតជាក់ស្តែងសំរាប់មុខសញ្ញានីមួយៗ និងត្រូវបញ្ជាក់នូវទីតាំង ភូមិ ឃុំ សង្កាត់ និងខ័ណ្ឌ ស្រុកអោយបានច្បាស់លាស់ ។

-ចំណាយទទួលភ្ញៀវ ទស្សនកិច្ច និងការប្រជុំត្រូវគ្រោងនៅក្នុងកំរិតសមស្រប ដែលមិនប៉ះពាល់ដល់ចំណាយចាំបាច់ និងមិនធ្វើអោយបាត់តុល្យភាពថវិកា ដូច្នេះចំពោះខេត្ត ក្រុង ដែលទទួលការឧបត្ថម្ភតុល្យភាពពីថវិការដ្ឋ គឺត្រូវគ្រោងការចំណាយនេះក្នុងកំរិតទាបជាទីបំផុត ។

១៣-សំណាកប័ត្រទាំងប៉ុន្មាននេះ មិនអាចធ្វើជាលិខិតយុត្តិការណ៍ចាំបាច់បានគ្រប់គ្រាន់ទេ វាគ្រាន់តែបង្ហាញជាមូលដ្ឋានសំរាប់ធ្វើអោយតារាងថវិកាមានភាពសមហេតុផល នៅក្នុងការគិតគូរ និងសមស្របទៅនឹងគោលដៅគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ សំណាកប័ត្រមានច្រើនបែបនេះ គឺសំរាប់ធានាអោយតារាងចំណាយផ្សេងៗគ្នា មានសុពលភាព និងសំរាប់ភ្ជាប់ជាមួយសំណុំឯកសារ ដើម្បីបង្ហាញពីថវិកាជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៤-ជាទូទៅ ចំណាយដំណើរការរដ្ឋបាល ទិញសំភារៈ ការថែទាំ និងការជួសជុលតូចៗ ត្រូវគិតគូរទៅតាមតំរូវការនៃកម្មវិធីសកម្មភាព ឬទៅតាមបទដ្ឋានសមស្រប ហើយសេវារបស់ខេត្ត ក្រុង ត្រូវជៀសវាងការបំប៉ោងតំណាងទានស្នើសុំ ។ ឥណទានសំរាប់ចំណាយជាអចិន្ត្រៃយ៍ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សំភារៈការិយាល័យ ប្រេងឥន្ធនៈ ត្រូវកំណត់អោយបានត្រឹមត្រូវ និងគ្រប់គ្រងដោយម៉ឺងម៉ាត់ ដើម្បីអោយមានការសន្សំសំចៃលើចំណាយប្រភេទនេះ ។ រីឯចំណាយផ្សេងៗទៀត ក៏ត្រូវតែគោរពតាមគោលការណ៍ សន្សំសំចៃដែរ ។

**ជំពូក១២ : ការឧបត្ថម្ភអោយអង្គភាពសាធារណៈរដ្ឋបាល**

១៥-នេះជាការឧបត្ថម្ភអោយឃុំ ភូមិ (សពភកប៉ុត្រ៦) និងអង្គភាពដែលគ្រប់គ្រងក្រោមរូបភាពជារដ្ឋាករ ឬជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានលក្ខណៈសេដ្ឋកិច្ច ...។ សំណើសុំចំណាយជំពូកនេះក៏ត្រូវមានលិខិតបញ្ជាក់ការណ៍ភ្ជាប់ជាមួយ ដូចគ្នានឹងជំពូក១០-១១ ខាងលើដែរ ( ចំណាយបុគ្គលិក និងចំណាយគ្រប់គ្រងរដ្ឋបាល ) ។

**ប្រភេទ៣ ចំណាយអន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌**

១៦-ចំណាយប្រភេទនេះ ចាំបាច់ត្រូវតែបរិយាយអោយបានច្បាស់លាស់ នូវអ្វីដែលទាក់ទងទៅនឹងគោលដៅដែលត្រូវធ្វើអោយបានសំរេច ។ ត្រូវពិនិត្យជ្រើសរើសចំណាយនេះ អោយបានអំពីចំពោះមុខសញ្ញារបស់អ្នកទទួលផល ទាំងចំនួនទឹកប្រាក់ដែលត្រូវពិនិត្យផ្តល់អោយ ។

**ប្រភេទ ៤ ចំណាយផ្សេងៗ និងចំណាយមិនបានគ្រោងទុក**

១៧-ចំណាយប្រភេទនេះ គឺជាការគ្រោងបំរុងសំរាប់ធានាការចំណាយចៃដន្យ ដែលមិនអាចគិតគូរបានពេលកសាងផែនការ ហើយជាទូទៅគឺត្រូវបានអនុញ្ញាតអោយគ្រោងពី ៣ទៅ៥ភាគរយ នៃសរុបចំណាយថវិកាទាំងមូល ។ ចំណាយនេះ អនុញ្ញាតអោយគ្រោងបានតែចំពោះខេត្ត ក្រុងណាដែលអាចធានាតុល្យភាពថវិការបស់ខ្លួនបាន ដោយមិនចាំបាច់ទទួលការឧបត្ថម្ភ តុល្យភាពពីថវិការដ្ឋប៉ុណ្ណោះ ។

**II.2- គំរោងចំណាយជាមូលធន :**

១៨-ចំណាយជាមូលធន ទាក់ទងជាគោលសំខាន់ទៅនឹងគំរោងចំណាយវិនិយោគ ដែលមានការត្រៀមត្រៀងគ្នាជាមុននិងសំដៅធ្វើអោយសំរេចគោលដៅដែលបានដាក់ចេញ ។

១៩-គំរោងវិនិយោគរបស់ខេត្ត ក្រុងដែលអនុវត្តបាន លុះត្រាតែគំរោងទាំងនោះបានដំណើរការស្របទៅតាមទំរង់បែបបទនៃកិច្ចដំណើរការគំរោងកម្មវិធីវិនិយោគសាធារណៈ ហើយដែលមានចុះក្នុងបញ្ជីទិន្នន័យ កម្មវិធីវិនិយោគសាធារណៈក្រសួងផែនការតែប៉ុណ្ណោះ ដូចមានណែនាំនៅក្នុងសារាចរអន្តរក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០១ ផក.កវស, ចុះថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំកម្មវិធីវិនិយោគសាធារណៈឆ្នាំ ២០០០-២០០២ ។

- ការវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស ដោយថវិកាខេត្ត ក្រុង គឺអាចគ្រោងបានក្នុងករណីដែលខេត្ត ក្រុងណាមានចំណូលផ្ទៃក្នុងខេត្ត ក្រុងជាមូលធន ។

-ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ គឺផ្អែកតាមជំនួយកម្មវិធី ឬ គំរោងការដែលអង្គការអន្តរជាតិ ឬ អង្គការក្រៅរដ្ឋាភិបាលនានាបានទៅទំនាក់ទំនងផ្ទាល់ជាមួយខេត្ត ក្រុង ដើម្បីកត់ត្រាចូលទៅក្នុងគំរោងថវិការបស់ខេត្ត - ក្រុង ទន្ទឹមនោះក៏ត្រូវយកចិត្តទុកដាក់កត់ត្រាការចំណាយឥណទានបដិភាគជារូបិយវត្ថុក្នុងប្រទេស នៃហិរញ្ញប្បទានពីបរទេសផ្ទាល់ទាំងនោះផងដែរ ។

## III. គំរោងចំណូល-ចំណាយ សរុប :

២០-គំរោងចំណូល-ចំណាយថវិការបស់ខេត្ត ក្រុងនីមួយៗដែលបានគិតគូរ គឺរួមមានទាំងការចំណាយ និងចំនួនចំណូលដែលមិនទាន់បានប្រមូលនៃការគ្រប់គ្រងពីឆ្នាំមុនផង ហើយត្រូវរៀបចំអោយមានគុណភាពពិតប្រាកដ និងស្ថិតក្នុងកញ្ចប់ថវិកា ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងបែងចែកជូននៅក្នុងកញ្ចប់ថវិការួមចំនួន ៥១.០០០លានរៀល ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ពេត្តលេខា និងត្រា

**គាត ឈន់**

★★★

ខេត្ត-ក្រុង ........ ឧបសម្ព័ន្ធទី១

# ការគ្រប់គ្រងឆ្នាំ ២០០០

## តារាងសរុបចំណូលថវិការបស់ខេត្ត ក្រុង

ឯកតា : លានរៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | វាក្យខ័ណ្ឌ | ការាយមុខចំណូល (តាមតារាងមាតិកាថវិកា) | ការគ្រប់គ្រងឆ្នាំ ១៩៩៩ | | | គំរោងឆ្នាំ ២០០០ |
|---|---|---|---|---|---|---|---|---|
| | | | | | ផែនការដើមឆ្នាំ | អនុវត្តឆមាសទី១ | ប៉ាន់ស្មានឆ្នាំ | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

ថ្ងៃទី ....... ខែ......... ឆ្នាំ ១៩៩...

អ្នកធ្វើតារាង

ថ្ងៃទី ....... ខែ......... ឆ្នាំ ១៩៩...

ពេត្តលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី ....... ខែ........ ឆ្នាំ ១៩៩...

ហត្ថលេខានិងត្រាអភិបាលខេត្ត

★★★

ខេត្ត-ក្រុង....

# ការគ្រប់គ្រងឆ្នាំ ២០០០

ឧបសម្ព័ន្ធទី២

## តារាងសរុបចំណាយថវិការបស់ខេត្ត ក្រុង

ឯកតា : លានរៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | អនុកថាខ័ណ្ឌ | នាមករណ៍មុខចំណាយ (តាមតារាងចាត់ថ្នាក់ថវិកា) | ការគ្រប់គ្រងឆ្នាំ ១៩៩៩ | | | គំរោងឆ្នាំ ២០០០ |
|---|---|---|---|---|---|---|---|---|
| | | | | | ផែនការដើមឆ្នាំ | អនុវត្តមកដល់ខែ៦ | ប៉ាន់ស្មានចុងឆ្នាំ | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |

ថ្ងៃទី ....... ខែ.........ឆ្នាំ ១៩៩...
អ្នកធ្វើតារាង

ថ្ងៃទី ....... ខែ.........ឆ្នាំ ១៩៩...
ហត្ថលេខា និង ត្រាប្រធានមន្ទីរ
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី ....... ខែ.........ឆ្នាំ ១៩៩...
ហត្ថលេខានិងត្រាអភិបាលខេត្ត

★★★

ខេត្ត-ក្រុង....

# ការគ្រប់គ្រងឆ្នាំ ២០០០

សមោធានបត្រ១

## តារាងសរុបនៃបុគ្គលិក បៀវត្ស និង ប្រាក់បំណាច់

***

| បុគ្គលិក / អង្គភាព | បៀវត្ស សរុប | ចំនួនបុគ្គលិក សរុប | ប្រភេទបុគ្គលិកដែលមានក្របខណ្ឌការគ្រប់គ្រងឆ្នាំ២០០០ | | | | បុគ្គលិក អណ្តែត | បុគ្គលិក ជាប់កិច្ចសន្យា |
|---|---|---|---|---|---|---|---|---|
| | | | បុ.អចិន្ត្រៃយ៍ សរុប | ប្រភេទ"ក" | ប្រភេទ"ខ" | ប្រភេទ"គ" | | |
| សរុប | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | |
| អង្គភាព | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| អង្គភាព | | | | | | | | |
| អង្គភាព | | | | | | | | |
| អង្គភាព | | | | | | | | |
| អង្គភាព | | | | | | | | |
| ............ | | | | | | | | |
| ............ | | | | | | | | |
| ............ | | | | | | | | |
| ............ | | | | | | | | |
| ............ | | | | | | | | |
| ............ | | | | | | | | |

★★★

ខេត្ត-ក្រុង ..........

# ការគ្រប់គ្រងឆ្នាំ ២០០០

## អសង្ហារិម : ជំពូក១១ – ប្រការ០១ – កថាខ័ណ្ឌ០១

សលាកប័ត្រ២

***

| អសង្ហារិម / អង្គភាព | សរុប | អសង្ហារិមប្រើប្រាស់ក្នុងរដ្ឋបាល | | | | អសង្ហារិមប្រើប្រាស់ក្នុងវិស័យសង្គម | | | |
|---|---|---|---|---|---|---|---|---|---|
| | | ០១ថ្លៃឈ្នួល | ០២ ការរៀបចំ | ០៣ ទឹក | ០៤ អគ្គិសនី | ០១ថ្លៃឈ្នួល | ០២ការរៀបចំ | ០៣ ទឹក | ០៤ អគ្គិសនី |
| សរុប | | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |
| អង្គភាព | | | | | | | | | |

# ការគ្រប់គ្រងឆ្នាំ ២០០០

## ចលនវត្ថុ-សំភារៈ និងសំភារៈការិយាល័យ

សលាកបត្រ ៣

ខេត្ត-ក្រុង....

## ជំពូក១១-ប្រការ០១-កថាខ័ណ្ឌ០២ និង ០៤

***

| អង្គភាព | សរុប | ចលនវត្ថុ និង សំភារៈ | | ក្រដាសបោះពុម្ពនិងគ្រឿងផ្គត់ផ្គង់ | |
|---|---|---|---|---|---|
| | | ការទិញ | ការថែទាំ | ក្រដាសបោះពុម្ព | សំភារៈការិយាល័យ |
| សរុប | | | | | |
| ខុទ្ទកាល័យ | | | | | |
| អង្គភាព | | | | | |
| អង្គភាព | | | | | |
| អង្គភាព | | | | | |
| អង្គភាព | | | | | |
| អង្គភាព | | | | | |
| ............. | | | | | |
| ............. | | | | | |
| ............. | | | | | |
| ............. | | | | | |
| ............. | | | | | |
| ............. | | | | | |
| ............. | | | | | |
| ............. | | | | | |

ខេត្ត-ក្រុង....

## ការគ្រប់គ្រង ឆ្នាំ២០០០

រថយន្ត : ជំពូក១១ - ប្រការ០១ - កថាខ័ណ្ឌ០៧ - វាក្យខ័ណ្ឌ០១ និង ០២ សលាកប័ត្រ៤

***

| អង្គភាព | សរុប | ម៉ាករថយន្ត | ផ្លាកលេខ | ឆ្នាំទិញ | ចំនួន គ.ម ដែលត្រូវរត់ | ការថែទាំ | ប្រេងឥន្ធនៈ និងប្រេងរំអិល |
|---|---|---|---|---|---|---|---|
| សរុប | | | | | | | |
| ខុទ្ទកាល័យ | | | | | | | |
| អង្គភាព | | | | | | | |
| អង្គភាព | | | | | | | |
| អង្គភាព | | | | | | | |
| អង្គភាព | | | | | | | |
| អង្គភាព | | | | | | | |
| ........ | | | | | | | |
| ........ | | | | | | | |
| ........ | | | | | | | |
| ........ | | | | | | | |
| ........ | | | | | | | |

★★★

## ការគ្រប់គ្រង ឆ្នាំ២០០០

ខេត្ត-ក្រុង.... ចំណាយធ្វើដំណើរឆោស៊ីយ : ជំពូក១១ - ប្រការ០២ សលាកប័ត្រ៥

***

| ប្រភេទបេសកកម្ម / អង្គភាព | សរុប | បេសកកម្មនៅក្នុងមណ្ឌល | | | បេសកកម្មអន្តរមណ្ឌល | | | បេសកកម្មក្រៅប្រទេស | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | សោ.ដឹកជញ្ជូន | សោ.បេសកកម្ម | សោ.ស្នាក់នៅ | សោ.ដឹកជញ្ជូន | សោ.បេសកកម្ម | សោ.ស្នាក់នៅ | សោ.ដឹកជញ្ជូន | សោ.បេសកកម្ម | សោ.ស្នាក់នៅ | សោ.ផ្សេងៗ |
| សរុប | | | | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | | | | |
| អង្គភាព | | | | | | | | | | | |
| អង្គភាព | | | | | | | | | | | |
| អង្គភាព | | | | | | | | | | | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| អង្គភាព | | | | | | | | | | | |
| អង្គភាព | | | | | | | | | | | |
| ........ | | | | | | | | | | | |
| ........ | | | | | | | | | | | |
| ........ | | | | | | | | | | | |
| ........ | | | | | | | | | | | |
| ........ | | | | | | | | | | | |
| ........ | | | | | | | | | | | |
| ......... | | | | | | | | | | | |

★★★

# ការគ្រប់គ្រងឆ្នាំ ២០០០

សលាកបត្រ៦

ខេត្ត-ក្រុង....

## ប្រាក់ឧបត្ថម្ភភូមិ ឃុំ : ជំពូក១២-ប្រការ០៣

***

| លរ | ឈ្មោះស្រុក ខណ្ឌ | សរុបប្រាក់ឧបត្ថម្ភ | ភូមិ | | ឃុំ សង្កាត់ | |
|---|---|---|---|---|---|---|
| | | | ចំនួន | ប្រាក់ឧបត្ថម្ភ | ចំនួន | ប្រាក់ឧបត្ថម្ភ |
| | សរុប | | | | | |
| ១ | ............... | | | | | |
| ២ | ............... | | | | | |
| ៣ | ............... | | | | | |
| | ............... | | | | | |
| | ............... | | | | | |
| | ............... | | | | | |
| | ............... | | | | | |
| | ............... | | | | | |
| | ............... | | | | | |
| | ............... | | | | | |

**សេចក្តីបញ្ជាក់ :**

| | | |
|---|---|---|
| **ប្រាក់ឧបត្ថម្ភប្រចាំខែក្នុងមួយសង្កាត់** | | ១៤១.០០០ ៛ |
| -ចៅសង្កាត់ | ១នាក់ គុណ ៣០.០០០ ៛ = | ៣០.០០០ ៛ |
| -ចៅសង្កាត់រង | ២នាក់ គុណ ២៧.០០០ ៛ = | ៥៤.០០០ ៛ |
| -ជំនួយការ | ២នាក់ គុណ ២៣.៥០០ ៛ = | ៤៧.០០០ ៛ |
| -ប្រាក់សំរាប់ដំណើរការរដ្ឋបាល | | ១០.០០០ ៛ |
| **ប្រាក់ឧបត្ថម្ភប្រចាំខែក្នុងមួយឃុំ** | | ១៤៤.៥០០ ៛ |
| -មេឃុំ | ១នាក់ គុណ ៣០.០០០ ៛ = | ៣០.០០០ ៛ |
| -ជំទប់ | ៣នាក់ គុណ ២៧.០០០ ៛ = | ៨១.០០០ ៛ |
| -ជំនួយការ | ១នាក់ គុណ ២៣.៥០០ ៛ = | ២៣.៥០០ ៛ |
| -ប្រាក់សំរាប់ដំណើរការរដ្ឋបាល | | ១០.០០០ ៛ |
| **ប្រាក់ឧបត្ថម្ភប្រចាំខែក្នុងមួយភូមិ** | | ២២.០០០ ៛ |
| -មេភូមិ | ១នាក់ គុណ ២២.០០០ ៛ = | ២២.០០០ ៛ |

★★★

## ២-សារាចរណែនាំ

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ១៩៩៩

### សារាចរណែនាំ លេខ ០១១ សហវ.ថ

**ស្តីពី បច្ចេកទេសនៃការរៀបចំគំរោងថវិកា**

**ឆ្នាំ ២០០០**

*****

ឆ្នាំ ២០០០ គឺជាសហស្សវត្សថ្មីសំរាប់ពិភពលោកទាំងមូល ហើយក៏ជាឆ្នាំដំបូងសំរាប់កម្ពុជា ទទួលបាននូវលទ្ធភាពពិសេសសំរាប់ការកសាងគំរោងថវិកា ឆ្នាំ២០០០ របស់ខ្លួន ។ អំណោយផលបានពីស្ថេរភាពនយោបាយជាតិ និងការវិលត្រឡប់របស់កម្ពុជាទៅក្នុងសហគមន៍អន្តរជាតិ បានផ្តល់នូវភាពសុទិដ្ឋិនិយមក្នុងការរៀបចំគំរោង ថវិកាជាតិឆ្នាំ ២០០០ ។

ដូច្នេះទស្សនៈនៃការគ្រប់គ្រងហិរញ្ញវត្ថុថវិកា ឆ្នាំ២០០០ ត្រូវតែមានវិធានការកែទំរង់តាមត្រូវការ ហើយដែលអាចចាប់ផ្តើមអនុវត្តបានចាប់តាំងពីថ្ងៃទី០១ ខែ មករា ឆ្នាំ ២០០០ នេះតទៅ ៖

-ប្រគល់ជូនក្រសួង ស្ថាប័នថ្នាក់រដ្ឋបាលកណ្តាលក្នុងការទទួលខុសត្រូវរៀបចំគំរោងឥណទាន និងបូកសរុបគំរោងនៃមណ្ឌលមន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត ក្រុងអោយទៅជាគំរោងថវិការបស់ក្រសួងអាណាព្យាបាល ។

-ប្រគល់ជូនអាណាប័កដើមខ្សែ ក្នុងការគ្រប់គ្រងឥណទានថវិកាដែលបានអនុម័តដោយស្ថាប័ននីតិបញ្ញត្តិទាំងពីរ និងធ្វើការបែងចែកឥណទាន ចលនាឥណទានផ្ទៃក្នុងជំពូក ដោយប្រកាសរបស់រដ្ឋមន្ត្រីដែលជាអាណាប័កដើមខ្សែ ក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-អាណាប័កដើមខ្សែត្រូវប្រទានសិទ្ធិជូនដល់ប្រធានមន្ទីរជំនាញ ខេត្ត ក្រុង ស្ថិតក្រោមឱវាទរបស់ខ្លួនក្នុងការបញ្ជាចំណូល និងបញ្ជាចំណាយ ។

-ការអនុវត្តន៍ចំណូលថវិការបស់រដ្ឋ ទាមទារនូវការកំណត់វិធានការតាមបែបបទបច្ចេកទេសនៅក្នុងក្របខ័ណ្ឌ នៃថវិកាឆ្នាំ ២០០០ ។ វិធានការទាំងនេះត្រូវឆ្លើយតបទៅនឹងគោលដៅពីរយ៉ាងគឺ ៖

+ តាមដានប្រកបដោយប្រសិទ្ធភាពនូវការប្រមូលចំណូល ដែលចាប់ផ្តើមចេញពីការកំណត់ពន្ធ ការប្រមូលពន្ធដែលបានធ្វើហើយ និងពន្ធដែលនៅសេសសល់ ត្រូវប្រមូលបន្ត ។

+ ប្រគល់ជូនរតនាគារជាតិនូវការទទួលខុសត្រូវ តាមដានអំពីការប្រមូលចំណូលពុំមែនសារពើពន្ធ ដោយមានការចូលរួមពីរដ្ឋទេយ្យករចំណូល ។ រដ្ឋទេយ្យករចំណូលនេះ ត្រូវបានជ្រើសរើសពីមន្ត្រីរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងតែងតាំងដោយប្រកាសអន្តរក្រសួង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធ ។

+ ធានានូវការថែរក្សាទុកចំណូលពុំមែនសារពើពន្ធនៅក្នុងបញ្ជីរបស់គណនេយ្យករសាធារណៈអោយបានគត់មត់ ។

ផ្អែកលើមូលដ្ឋាននេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានកិត្តិយសសូមធ្វើការណែនាំពីលក្ខណៈបច្ចេកទេសនៃការរៀបចំគំរោងថវិកាឆ្នាំ ២០០០ ជាពិសេសបង្ហាញជូននូវនីតិវិធី និងទំរង់បែបបទនៃការរៀបចំគំរោងថវិកា ព្រមទាំងវិធានទាំងឡាយដែលត្រូវអនុវត្តក្នុងការគិតគូរគំរោងចំណូល ចំណាយថវិកា ។ ជាដំបូងចាំបាច់ត្រូវកំណត់នូវទិសដៅ នៃនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលគ្របដណ្តប់ទៅលើគំរោងថវិកាថ្មីនេះ សំដៅឆ្លុះបញ្ចាំងអោយឃើញច្បាស់លាស់នូវភារកិច្ចរបស់ប្រទេសជាតិ និងកំណត់នូវយុទ្ធសាស្ត្រសមស្រប ដើម្បីសំរេចនូវភារកិច្ចទាំងនោះ ។

**I-នយោបាយ និងទិសដៅនៃថវិកា : *ការបកស្រាយខាងបច្ចេកទេស***

១-ថវិកាជាឧបករណ៍សំរាប់ធ្វើអោយសំរេចនូវនយោបាយ ឯនយោបាយកំណត់នូវទិសដៅ ។ មានទិសដៅ ហើយត្រូវកំណត់យុទ្ធសាស្ត្រដែលសំដែងចេញជាផែនការសកម្មភាព ។ ការរៀបចំថវិកាទាំងអស់ ត្រូវតែប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌនេះ ។ អាស្រ័យហេតុនេះការរៀបចំថវិកាឆ្នាំ ២០០០ ត្រូវតែសំរេចបើគោលដៅ និង

យុទ្ធសាស្ត្រដែលត្រូវបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ១៩៩៦ - ២០០០ ហើយត្រូវតែគោរពតាមអាទិភាពជាតិ ។

២-ដូច្នេះការរៀបចំគំរោងថវិកាមិនមែនជាកិច្ចប្រតិបត្តិការគណនេយ្យមួយសាមញ្ញនោះទេ គឺត្រូវផ្តើមចេញពីកម្មវិធីដែលត្រូវអនុវត្ត និងកិច្ចដំណើរការដែលត្រូវធ្វើអោយបានសំរេច ។ ជាក់ស្តែង ថវិកាត្រូវតែបង្ហាញនូវកម្មវិធីវិនិយោគនៃចំណាយទាំងនេះ ។ សេចក្តីត្រូវការរបស់ក្រសួងស្ថាប័ននានា ត្រូវតែបង្ហាញអោយឃើញនូវការងារ និងសេវាដែលត្រូវធ្វើ គឺមិនមែនបង្ហាញតែឥណទានថវិកាជាតួលេខសុទ្ធនោះទេ ។ ការងារដែលត្រូវអនុវត្តសំរាប់សកម្មភាពនីមួយៗ គឺសុទ្ធតែស្ថិតនៅក្នុងកម្មវិធី ដែលសំដៅធ្វើអោយសំរេចនូវគោលដៅដែលបានដាក់ចេញនោះ ។ តំរូវការនៃឥណទានថវិកា គឺត្រូវផ្តើមចេញពីតំរូវការនៃសេវាបុគ្គលិក និងសំភារៈចាំបាច់ ដូចដែលធ្លាប់បានធ្វើក្នុងការពិភាក្សាថវិកា នាបណ្តាឆ្នាំកន្លងទៅ ។ ហេតុនេះការពិភាក្សាថវិកាឆ្នាំ ២០០០ និងប្រព្រឹត្តទៅដោយផ្អែកលើកម្មវិធីសកម្មភាពរបស់ក្រសួងស្ថាប័ននីមួយៗមិនមែនផ្អែកតែលើការប៉ាន់ប្រមាណនៃឥណទាននោះទេ ។

## II-ការវិវត្តន៍រួមនៃថវិកា

៣-សូមបង្ហាញនូវការវិវត្តន៍នៃថវិកានៅក្នុងរយៈពេលវែង ទៅតាមបណ្តា ឆ្នាំដូចតទៅ ៖

-ឆ្នាំកំពុងប្រព្រឹត្តទៅ (n-1) (ឆ្នាំ ១៩៩៩)

-ពីរឆ្នាំកន្លងមក (n-2) និង (n-3)

-ឆ្នាំផែនការ ( n ) និង (ឆ្នាំ ២០០០ )

-ពីរឆ្នាំបន្ទាប់ (n+1) និង (n+2)

-តារាង២ជាគំរូសំរាប់បង្ហាញនូវការវិវត្តន៍នៃថវិកា ៖

-ចំណាយសរុបតាមក្រសួងស្ថាប័ននីមួយៗ

-សមាមាត្រចំណាយនៅក្នុងសរុបចំណាយថវិកាជាប្រចាំ

-និងសមាមាត្រចំណាយនៅក្នុង ផ.ស.ស.

បន្ទាប់មកត្រូវបង្ហាញនូវ ៖

-ចំណាយតាមជំពូក នៅក្នុងសរុបចំណាយតាមក្រសួងស្ថាប័ននីមួយៗ

-និងអត្រាកំណើន ។

## III-ការរៀបចំ និងការពិភាក្សាសំណើនានា

៤-គំរោងថវិកាត្រូវតែគិតគូរប្រមូលផ្តុំ និងបង្ហាញឡើងតាមនាយកដ្ឋាននីមួយៗ តាមមន្ទីរជំនាញខេត្ត-ក្រុង និងតាមមុខងារ ។

៥-ថវិកាកំពុងប្រព្រឹត្តទៅ (n-1) ឆ្នាំ ១៩៩៩ ដែលរដ្ឋសភាបានអនុម័ត ត្រូវធ្វើការកែសម្រួលដើម្បីធ្វើជាមូលដ្ឋាននៃការរៀបចំថវិកាឆ្នាំ ២០០០ (n) សំរាប់អោយគេវាស់ការគណនានានាដំណើរការបានល្អ ។ ក្នុងករណីដែលមានសកម្មភាពការងារដូចមុនក្រសួង ស្ថាប័នត្រូវគិតគូរឡើងវិញនូវថវិកានៃឆ្នាំកំពុងប្រព្រឹត្តទៅ ដោយគ្រាន់តែកែសម្រួលទៅតាមតម្រូវការចាំបាច់ដែលទាក់ទងទៅនឹងមូលហេតុដូចតទៅ ៖

-ចលនានៃឥណទាន ដែលបានធ្វើឡើងនៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅដូចជា ៖

+ការបង្វែរឥណទានថវិកាផ្ទៃក្នុងជំពូក ឬពីជំពូកមួយទៅជំពូកមួយទៀត ដែលធ្វើអោយការបែងចែកក្នុងឥណទាន ដើមនៃក្រសួងស្ថាប័នមានការប្រែប្រួល ។

+ផ្ទេរទាយជ្ជទាន នៃឥណទានបន្ថែមសំរាប់ផលប្រយោជន៍របស់ក្រសួង ស្ថាប័ន ។

-អានុភាពជាហេតុនៃអតិផរណានៅក្នុងឆ្នាំ អត្រាកើនថ្លៃនៃផលិតផលចាំបាច់ ដូចជាអគ្គិសនី ទឹក ប្រេងឥន្ធនៈ សោហ៊ុយដឹកជញ្ជូន របបចំណាយរដ្ឋបាល ..... ។ល។

-ការបង្កើន ឬបន្ថយក្របខ័ណ្ឌ ដែលសំរេចអនុម័ត ដោយលិខិតបទដ្ឋាន ។ ការកែសម្រួលទាំងអស់នេះ លើថវិកាឆ្នាំ ១៩៩៩ ធ្វើជាមូលដ្ឋានសំរាប់រៀបចំថវិកា ឆ្នាំ ២០០០ ។

៦-គំរោងថវិការបស់ក្រសួងស្ថាប័ន ត្រូវតែបញ្ជាក់នូវមូលហេតុច្បាស់លាស់ ដូចបានជំរាបជូនខាងលើនេះ ហើយរាល់ការពន្យល់ទាំងអស់ ត្រូវតែមាននៅក្នុងតារាងភ្ជាប់មកជាមួយលិខិតនេះ ។ រាល់កង្វះឥណទានថវិកា នៅក្នុងឆ្នាំកំពុងប្រព្រឹត្តទៅដែលអាចយកមកពិភាក្សាបាន លុះត្រាតែមាននៅក្នុងក្របខ័ណ្ឌកម្មវិធីសកម្មភាពនៃឆ្នាំផែនការ ។

៧-ឥណទានថវិកាដែលបានគិតគូរ ដោយផ្អែកលើមូលដ្ឋានខាងលើនេះ នឹងមានការប្រែប្រួល អាស្រ័យដោយមានការពង្រីកកម្មវិធីសកម្មភាពនៃឆ្នាំកំពុងប្រព្រឹត្តទៅ ឬមានកម្មវិធីសកម្មភាពថ្មី ដែលត្រូវចាប់ផ្ដើមអនុវត្តនៅក្នុងឆ្នាំកំពុងរៀបចំ ។ តារាង៥ គឺជាតារាងរៀបរាប់នូវកម្មវិធីសកម្មភាព ចំនួនបុគ្គលិក និងអង្គភាពទទួលបន្ទុកអនុវត្ត ។ ផ្នែកទី២ នៃតារាងនេះបានបែងចែកចំណាយ តាមជំពូកថវិកា ។ តារាង៦ គឺជាតារាងប្រៀបធៀបឥណទានតាមកម្មវិធី និងតាមអង្គភាពដែលបានបង្ហាញនូវឥណទានដែលបានផ្ដល់អោយក្នុងឆ្នាំ ១៩៩៩ និងគំរោងឥណទានស្នើសុំសំរាប់ ឆ្នាំ ២០០០ ។ ការខុសគ្នារវាងឆ្នាំទាំង២ និងអត្រានៃការប្រែប្រួលឥណទាន គឺអាស្រ័យដោយការអភិវឌ្ឍន៏កម្មវិធី ឬមានកម្មវិធីថ្មី ។

៨-បច្ចេកទេសវិភាគដទៃទៀត គឺយកចំណាយថវិកាឆ្នាំមុន ដូចជាចំណាយដំណើរការរដ្ឋបាលសំរាប់មន្ត្រីរាជការម្នាក់ៗ ទ្រង់ទ្រាយនៃចំណាយ ប្រភពនៃការចំណាយ និងផលប្រយោជន៍របស់ចំណាយចាំបាច់មួយចំនួនសំរាប់ធ្វើជាមូលដ្ឋានគ្រោងគិតឆ្នាំថ្មី ។

៩-សរុបឥណទានថវិកាចាំបាច់ របស់ក្រសួងស្ថាប័ននីមួយៗ ត្រូវតែឈរទៅលើ ៖

-គោលដៅរបស់ក្រសួងស្ថាប័ននីមួយៗ

-សមិទ្ធភាពរបស់ខ្លួន

-កម្មវិធីដែលត្រូវចាប់ផ្តើមអនុវត្ត

-មធ្យោបាយដំណើរការ

-និងវិធានការនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពខ្ពស់

## IV-នីតិវិធី និងបច្ចេកទេសនៃការរៀបចំ ថវិកាឆ្នាំ ២០០០

ក-របៀបគិតគូរចំណូល ចំណាយថវិកា ឆ្នាំ ២០០០

១០-នីតិវិធី និងបច្ចេកទេសនៃការរៀបចំថវិកាឆ្នាំកន្លងទៅ គឺស្ថិតនៅជាធរមានសំរាប់ឆ្នាំ២០០០ ពិសេស ចំពោះអ្វីដែលទាក់ទងទៅនឹង ៖

-ការគិតគូរចំណូលជាប្រចាំ និងចំណូលជាមូលធន

-ការគិតគូរឥណទានថវិកា ត្រូវផ្តើមចេញពីតំរូវការជាក់ស្តែង និងដោយផ្ទាល់ ដោយផ្អែកទៅលើកត្តាដែលទាក់ទងទៅនឹងការចំណាយ ដូចជាតារាងបុគ្គលិក បញ្ជីប៉ាន់ស្មានតំលៃសំភារៈ ឬការដេញថ្លៃផ្គត់ផ្គង់សំភារៈ ............ និងត្រូវផ្អែកទៅតាមធម្មនិយាម ចំណាយសមស្របដែលមានកន្លងមក ដូចជាចំណាយលើថ្លៃម្ហូបរបស់អ្នកជំងឺនៅមន្ទីរពេទ្យ ចំណាយខាងការសិក្សាសំរាប់សិស្ស ឬនិស្សិតម្នាក់ ឬត្រូវផ្អែកទៅតាមតួលេខស្ថិតិជាមធ្យមភាគរបស់គណនេយ្យថវិកាសំរាប់ការគ្រប់គ្រងកន្លងមក ។

១១-ជាទូទៅ ចំពោះចំណាយទាំងអស់សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ត្រូវតែមានការវិភាគយ៉ាងល្អិតល្អន់ និងមានលិខិតបញ្ជាក់ហេតុផលភ្ជាប់មកជាមួយ ដើម្បីពន្យល់តាមជំពូក តាមប្រការ ទៅតាមតារាងគំរូ ដូចដែលធ្លាប់ធ្វើកន្លងមកសំរាប់ធ្វើជាមូលដ្ឋាននៃការពិភាក្សា ។

១២-ដោយឡែកជំពូក១១ នៃថវិកាជាជំពូកប្រមូលផ្តុំនូវការចំណាយខាងសំភារៈ និងការគ្រប់គ្រងនៃរដ្ឋបាលថ្នាក់កណ្តាល សំរាប់ដំណើរការរបស់ក្រសួងស្ថាប័ន និងមន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត-ក្រុង ។ ចំពោះឥណទានរបស់អង្គភាពនៅរដ្ឋបាលកណ្តាលក្តី និងមន្ទីរជំនាញរបស់ខ្លួននៅខេត្ត-ក្រុងក្តី ត្រូវតែមានភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ហេតុផលត្រឹមត្រូវច្បាស់ ដើម្បីអោយងាយពិនិត្យការខុសគ្នារវាងនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ ។ ការបែងចែកតាមនាយកដ្ឋាន ឬ អង្គភាពមាននៅក្នុងតារាងដែលភ្ជាប់មកជាមួយសារាចរនេះ ។

ខ-ការកំណត់កញ្ចប់ថវិកាឆ្នាំ ២០០០ (**Enveloppe Budgetaire**)

១៣-ផ្អែកតាមទិន្នន័យក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការកំណត់សំរាប់ក្រសួងស្ថាប័ន និងមន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត ក្រុង នូវកញ្ចប់ថវិកា ដូចបានភ្ជាប់មកជាមួយនេះ ។

កញ្ចប់ថវិកានេះ គឺជាតួលេខសរុបខ្ពស់បំផុត នៃចំណាយជាប្រចាំ សំរាប់អោយក្រសួងស្ថាប័ន និងមន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត ក្រុងនីមួយៗ ធ្វើការបែងចែកលំអិតទៅតាមជំពូក ប្រការ កថាខ័ណ្ឌ

វាក្យខ័ណ្ឌ នៃមាតិកាថវិកា ព្រមទាំងត្រូវផ្អែកតាមកម្មវិធីសកម្មភាព និងផែនអាទិភាពរបស់ខ្លួនសំរាប់ឆ្នាំ២០០០ ។ ប្រការដែលត្រូវយកចិត្តទុកដាក់ក្នុងការបែងចែកកញ្ចប់ថវិកាមានដូចតទៅ ៖

-ចំណាយបុគ្គលិកត្រូវគ្រោងទៅតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងនៅ ឆ្នាំ១៩៩៩ ។ ចំនួនមន្ត្រីរាជការដែលជ្រើសរើសត្រូវមានសេចក្តីសំរេចរបស់គណៈរដ្ឋមន្ត្រី ដោយផ្អែកតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ លាលែងពីក្របខ័ណ្ឌរដ្ឋ និង មរណភាព ត្រូវកាត់បន្ថយពីអង្គភាពខ្លួន ។

-ចំណាយដំណើរការរដ្ឋបាល ទិញសំភារៈ និងជួសជុលតូច មិនត្រូវគ្រោងអោយកើនឡើងមួយជាពីរ ឬបីដង នៃឆ្នាំចាស់ ដោយគ្មានមូលដ្ឋានទេ គឺត្រូវផ្អែកទៅតាមកម្មវិធីសកម្មភាព និងធម្មនិយាម ដូចបានជំរាបជូនខាងលើ ដើម្បីតម្រឹមអោយនៅក្នុងកញ្ចប់ថវិកានេះ ។ ត្រូវយកចិត្តទុកដាក់គ្រប់គ្រងសោហ៊ុយចំណាយជាអចិន្ត្រៃយ៍ ដូចជាទូរស័ព្ទ អគ្គិសនី ទឹក សំភារៈការិយាល័យ ប្រេងឥន្ធនៈ ទម្លាយផ្លូវ .... ។ល។ ដើម្បីបន្ថយចំណាយនេះនៅក្នុងកំរិតមួយសមគួរ ។

-ចំណាយផ្នែកផ្សេងៗទៀត ត្រូវគ្រោងទៅតាមការចាំបាច់ និងត្រូវស្ថិតនៅក្នុងកញ្ចប់ថវិកានេះដែរ ។

១៤-កញ្ចប់ថវិកានឹងធ្វើជាកម្មវត្ថុនៃការពិភាក្សានៅក្នុងកិច្ចប្រជុំរៀបចំថវិការបស់ក្រសួងស្ថាប័ន និងមន្ទីរជំនាញខេត្ត-ក្រុង ។ ដូច្នេះតួលេខនៃកញ្ចប់ថវិកាដែលបានកំណត់ដូចនេះ អាចនឹងមានការប្រែប្រួលកើនឡើង ឬថយចុះខ្លះក្នុងល័ក្ខខ័ណ្ឌដែលកញ្ចប់រួមនៃថវិកាជាតិ មិនមានការផ្លាស់ប្តូរ លើកលែងតែមានចំណូលថ្មីមកបន្ថែមទៀត ។

១៥-គំរោងចំណូលចំណាយថវិកាខេត្ត-ក្រុង ត្រូវប្រតិបត្តិទៅតាមនីតិវិធី និងបច្ចេកទេសនៃការរៀបចំថវិការដ្ឋដែរ ។

១៦-ដោយឡែកចំណាយវិនិយោគសាធារណៈ ដោយហិរញ្ញប្បទានក្នុងប្រទេស និងក្រៅប្រទេសផ្ទាល់ ក្រសួងស្ថាប័ន និងមន្ទីរជំនាញខេត្ត-ក្រុងទាំងអស់ ត្រូវកសាងគំរោងចំណាយនេះ ដោយផ្អែកទៅតាមកម្មវិធីវិនិយោគសាធារណៈ (PIP) រំកិលបីឆ្នាំ ដែលបានរៀបចំឡើងដោយក្រសួងផែនការ ក្រុមប្រឹក្សាអភិវឌ្ឍន៍ កម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៧-ពេលទទួលបាននូវការណែនាំនេះ ក្រសួងស្ថាប័ន និងមន្ទីរជំនាញរបស់ខ្លួននៅតាមខេត្ត ក្រុង និងសាលាខេត្ត-ក្រុង ត្រូវយកចិត្តទុកដាក់រៀបចំនូវគំរោងចំណូល ចំណាយថវិការបស់ខ្លួនសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ទៅតាមតារាងគំរូដែលផ្ញើជូនភ្ជាប់មកជាមួយនេះ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួនពីរច្បាប់ យ៉ាងយូរបំផុតត្រឹមថ្ងៃទី២៣ ខែ កក្កដា ឆ្នាំ ១៩៩៩ (សំរាប់នាយកដ្ឋានថវិកា មួយច្បាប់ និងនាយកដ្ឋានហិរញ្ញកិច្ច

មួយក្បាល) ។ តួលេខតារាងចំណូល ចំណាយថវិកា ត្រូវសរសេរជាលេខអន្តរជាតិ (1.2.3....) ហើយឯកតាគិតទាបបំផុត 0.1 លានរៀល ។

ក្នុងការអនុវត្តន៍សារាចរណែនាំនេះ បើក្រសួងស្ថាប័ន មន្ទីរជំនាញខេត្ត ក្រុង និងសាលាខេត្ត ក្រុង មានចំណុចណាមួយមិនទាន់ច្បាស់លាស់ សូមមកទំនាក់ទំនងដោះស្រាយជាបន្ទាន់ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ហត្ថលេខានិងត្រា
**គាត ឈន់**

★★★

## ប្រតិទិនប្រជុំពិភាក្សាការពារគំរោងថវិកា ឆ្នាំ ២០០០
## របស់ក្រសួង ស្ថាប័ន រដ្ឋបាលកណ្តាល និង មន្ទីរជំនាញ ខេត្ត ក្រុង

★★★

| ល.រ | ក្រសួង ស្ថាប័ន | កាលបរិច្ឆេទ | ផ្សេងៗ |
|---|---|---|---|
| | *ក/ ផ្នែករដ្ឋបាលទូទៅ* | | |
| ១ | ព្រះបរមរាជវាំង | ថ្ងៃច័ន្ទ ទី០២ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ៨ និង៣០ ដល់ម៉ោង១១ | |
| ២ | រដ្ឋសភា | ថ្ងៃច័ន្ទ ទី០២ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ១៤ និង៣០ ដល់ម៉ោង១៧ | |
| ៣ | ព្រឹទ្ធសភា | ថ្ងៃអង្គារ ទី០៣ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ៨ និង៣០ ដល់ម៉ោង១១ | |
| ៤ | ក្រុមប្រឹក្សាធម្មនុញ្ញ | ថ្ងៃអង្គារ ទី០៣ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ១៤ និង៣០ ដល់ម៉ោង១៧ | |
| ៥ | ទីស្តីការគណៈរដ្ឋមន្ត្រី | ថ្ងៃពុធ ទី០៤ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ៨ និង៣០ ដល់ម៉ោង១១ | |
| ៦ | រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ថ្ងៃពុធ ទី០៤ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ១៤និង៣០ ដល់ម៉ោង១៧ | |
| ៧ | ក្រសួងការបរទេស | ថ្ងៃព្រហស្បត្តិ៍ ទី០៥ ខែ សីហា ឆ្នាំ១៩៩៩ ពីម៉ោង ៨និង៣០ ដល់ម៉ោង១១ | |
| ៨ | ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច | ថ្ងៃព្រហស្បត្តិ៍ ទី០៥ ខែសីហា ឆ្នាំ ១៩៩៩ ពីម៉ោង១៤និង៣០ដល់ម៉ោង១៧ | |
| ៩ | យុត្តិធម៌ សាលាឧទ្ធរណ៍ តុលាការកំពូល | ថ្ងៃសុក្រ ទី០៦ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ១៤ និង៣០ ដល់ម៉ោង១១ | |
| ១០ | ក្រសួងផែនការ | ថ្ងៃសុក្រ ទី០៦ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ១៤ និង៣០ ដល់ម៉ោង១៧ | |
| ១១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ថ្ងៃច័ន្ទ ទី០៩ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ៨ និង៣០ ដល់ម៉ោង១១ | |
| ១២ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ថ្ងៃច័ន្ទ ទី០៩ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ១៤ និង៣០ ដល់ម៉ោង១៧ | |
| ១៣ | ក្រសួងបណ្តាផ្នែក "រដ្ឋបាលទូទៅ" | ថ្ងៃអង្គារ ទី១០ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ៨ និង៣០ ដល់ម៉ោង១១ | |
| ១៤ | គ.ជ.ប. | ថ្ងៃអង្គារ ទី១០ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ១៤ និង៣០ ដល់ម៉ោង១៧ | |
| | ខ/ *ផ្នែករដ្ឋបាលសង្គមកិច្ច* | | |
| ១៥ | ក្រសួងសុខាភិបាល | ថ្ងៃពុធ ទី១១ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ៨ និង៣០ ដល់ម៉ោង១១ | |
| ១៦ | ក្រសួងបរិស្ថាន | ថ្ងៃពុធ ទី១១ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ១៤ និង៣០ ដល់ម៉ោង១៧ | |
| ១៧ | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | ថ្ងៃព្រហស្បត្តិ៍ ទី១២ ខែ សីហា ឆ្នាំ១៩៩៩ ពីម៉ោង៨ និង៣០ ដល់ម៉ោង១១ | |

| | | | |
|---|---|---|---|
| ១៨ | ក្រសួងពត៌មាន | ថ្ងៃព្រហស្បតិ៍ ទី១២ ខែ សីហា ឆ្នាំ១៩៩៩ ពីម៉ោង១៤ និង៣០ដល់ម៉ោង១៧ | |
| ១៩ | ក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាល ... | ថ្ងៃសុក្រ ទី១៣ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ៨ និង៣០ ដល់ម៉ោង១១ | |
| ២០ | ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន | ថ្ងៃសុក្រ ទី១៣ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ១៤ និង៣០ ដល់ម៉ោង១៧ | |
| ២១ | ក្រសួងអប់រំយុវជន និងកីឡា | ថ្ងៃច័ន្ទ ទី១៦ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ៨ និង៣០ ដល់ម៉ោង១១ | |
| ២២ | ក្រសួងធម្មការ និងសាសនា | ថ្ងៃច័ន្ទ ទី១៦ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង១៤ និង៣០ ដល់ម៉ោង១៧ | |
| | គ/ *ផ្នែករដ្ឋបាលសេដ្ឋកិច្ច* | | |
| ២៣ | ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល | ថ្ងៃអង្គារ ទី១៧ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ៨ និង៣០ ដល់ម៉ោង១១ | |
| ២៤ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ថ្ងៃអង្គារ ទី១៧ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ១៤ និង៣០ ដល់ម៉ោង១៧ | |
| ២៥ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ថ្ងៃពុធ ទី១៨ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ៨ និង៣០ ដល់ម៉ោង១១ | |
| ២៦ | ក្រសួងពាណិជ្ជកម្ម | ថ្ងៃពុធ ទី១៨ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ១៤ និង៣០ ដល់ម៉ោង១៧ | |
| ២៧ | ក្រសួងទេសចរណ៍ | ថ្ងៃព្រហស្បតិ៍ ទី១៩ ខែ សីហា ឆ្នាំ១៩៩៩ ពីម៉ោង៨និង៣០ ដល់ម៉ោង១១ | |
| ២៨ | ក្រសួងអភិវឌ្ឍន៍ជនបទ | ថ្ងៃព្រហស្បតិ៍ ទី១៩ ខែ សីហាឆ្នាំ១៩៩៩ ពីម៉ោង ១៤និង៣០ដល់ម៉ោង១៧ | |
| ២៩ | ក្រសួងសាធារណការនិងដឹកជញ្ជូន | ថ្ងៃសុក្រ ទី២០ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ៨ និង៣០ ដល់ម៉ោង១១ | |
| ៣០ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | ថ្ងៃសុក្រ ទី២០ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ១៤ និង៣០ ដល់ម៉ោង១៧ | |
| ៣១ | ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ | ថ្ងៃច័ន្ទ ទី២៣ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ១៤ និង៣០ ដល់ម៉ោង១៧ | |
| ៣២ | ក្រសួងធនធានទឹក និង ឧតុនិយម | ថ្ងៃច័ន្ទ ទី២៣ ខែ សីហា ឆ្នាំ ១៩៩៩ ពីម៉ោង ១៤ និង៣០ ដល់ម៉ោង១៧ | |
| | ឃ/ ផ្នែកយោធា និង សន្តិសុខ | | |
| ៣៣ | ក្រសួងការពារជាតិ | ថ្ងៃអង្គារ ទី២៤ ខែសីហា ឆ្នាំ១៩៩៩ ពីម៉ោង ៨និង៣០ ដល់ម៉ោង ១១ | |
| ៣៤ | ក្រសួងមហាផ្ទៃ "សន្តិសុខសាធារណៈ" | ថ្ងៃអង្គារទី២៤ ខែសីហា ឆ្នាំ១៩៩៩ ម៉ោង១៤ និង៣០ ដល់ម៉ោង ១៧ | |

★★★

## ប្រតិទិននៃការរៀបចំគំរោងថវិកាជាតិឆ្នាំ ២០០០

***

| កាលបរិច្ឆេទ | បរិយាយ |
|---|---|
| -១៥ មិថុនា ដល់ ៣០ មិថុនា ១៩៩៩ | • សិក្សាអំពី Cardre Macro-Economique<br>• ប្រជុំរវាងនាយកដ្ឋានថវិកា ជាមួយអង្គភាពចំណូលទាំងអស់ ដែលចំណុះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីធ្វើតួលេខចំណូលក្នុងប្រទេសព័យាករបឋម ។<br>• ធ្វើសារាចរណែនាំអំពីនយោបាយ និង បច្ចេកទេសនៃការរៀបចំគំរោងថវិកាឆ្នាំ ២០០០ ។ |
| -០២ កក្កដា | • បញ្ជូនសារាចរណែនាំបច្ចេកទេសទៅក្រសួង-ស្ថាប័ន មន្ទីរជំនាញ និងសាលាខេត្ត-ក្រុងទូទាំងប្រទេស ។ |
| -២៦ កក្កដា ១៩៩៩ | • ប្រមូលគំរោងថវិកា និង ធ្វើការបូកសរុប ។ |

| | |
|---|---|
| -០២ សីហា ដល់ ២៥ សីហា ១៩៩៩ | • ប្រជុំពិភាក្សាការពារគំរោងរបស់ក្រសួង ស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ។ |
| -២៥ សីហា ដល់ ១៥ កញ្ញា ១៩៩៩ | • ប្រជុំរវាងនាយកដ្ឋានថវិកា និងអង្គភាពចំណូលលើកទី២ ដើម្បីធ្វើតុល្យភាពចំណូល ចំណាយ ។ |
| | • ចងក្រងរៀបបញ្ចូលឯកសារ PIP ទៅក្នុងគំរោង និងតំឡើងគំរោងច្បាប់ថវិកា ឆ្នាំ ២០០០ (Complet) ។ |
| -១៦ កញ្ញា ដល់ ១៥ តុលា ១៩៩៩ | • ឆ្លងឯកសារថវិកា នៅគណៈរដ្ឋមន្ត្រី ។ |
| ១៦ តុលា ដល់ ១៥ វិច្ឆិកា ១៩៩៩ | • ឆ្លងឯកសារថវិកា នៅរដ្ឋសភា ។ |
| ១៦ វិច្ឆិកា ដល់ ៣០ វិច្ឆិកា ១៩៩៩ | • ឆ្លងឯកសារថវិកា នៅព្រឹទ្ធសភា ។ |
| ខែ ធ្នូ ១៩៩៩ | • ច្បាប់ថវិកា ត្រូវបានអនុម័ត ។ |
| | • ធ្វើ និងបញ្ជូនអនុក្រឹត្យ សារាចរណែនាំអនុវត្ត និង ប្រកាសឥណទានថវិកា ឆ្នាំ ២០០០ ។ |

រាជធានីភ្នំពេញ , ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៩

ប្រធាននាយកដ្ឋានថវិកា

ហត្ថលេខា និងត្រា

**នួន ឡេង**

★★★

## តារាងកំណត់តួលេខច្បាប់ថវិកាចំណាយជាប្រចាំសំរាប់ ក្រសួង ស្ថាប័នថ្នាក់កណ្តាល និងមន្ទីរជំនាញ ខេត្ត ក្រុង សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០

***

ឯកតា : លានរៀល

| លេខ កូដ | ក្រសួងស្ថាប័ន | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៩ | | | | គំរោងចំណាយថវិកា ឆ្នាំ ២០០០ | | | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ជាតិ | ខេត្ត ក្រុង | %ផសស | កញ្ចប់ថវិកា | ជាតិ | ខេត្ត ក្រុង | %ផសស | |
| | សរុបចំណាយចរន្ត | ១.១០០.០០០ | ៨៧៦.១០០ | ២២៣.៩០០ | ៩,០៧ | ១.២៤៥.០០០ | ៩៦០.៣៨០ | ២៨៤.៦២០ | ៩,៣៣ | |
| | ១-វិស័យរដ្ឋបាល | ១៥៤.២១៥ | ១៤៨.៩៤០ | ៥.៦៧៥ | ១,២០ | ១៥១.៣៤០ | ១៤៤.៩៤០ | ៦.៤០០ | ១,១៣ | |
| ០១ | ព្រះបរមរាជវាំង | ១៧.០០០ | ១៧.០០០ | | ០,១៤ | ១៤.០០០ | ១៤.០០០ | | ០,១៣ | |
| ០២ | រដ្ឋសភា | ១២.៨០០ | ១២.៨០០ | | ០,១១ | ១៤.១០០ | ១៤.១០០ | | ០,១០ | |
| ០៣ | ព្រឹទ្ធសភា | ៦.៩០០ | ៦.៩០០ | | ០,០៤ | ៧.៣០០ | ៧.៣០០ | | ០,០៥ | |
| ០៤ | ក្រុមប្រឹក្សាធម្មនុញ្ញ | ១.៧០០ | ១.៧០០ | | ០,០១ | ២.១០០ | ២.១០០ | | ០,០២ | |
| ០៥ ១ | ទីស្តីការគណៈរដ្ឋមន្ត្រី | ៩០.២៧០ | ៩០.២៧០ | | ០,៣៨ | ៣២.៩៦០ | ៣២.៩៦០ | | ០,២៩ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ០៥ ២ | មុខងារសាធារណៈ | ៣៥០ | ៣៥០ | | ០,០០ | ៤៧០ | ៤៧០ | | ០,០០ | |
| ០៥ ៤ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ១.៦០០ | ១.៦០០ | | ០,០១ | ២.០០០ | ២.០០០ | | ០,០១ | |
| ០៧ ២ | មហាផ្ទៃ "រដ្ឋបាលទូទៅ" | ៥.០០០ | ៥.០០០ | | ០,០៣ | ៥.១០០ | ៥.១០០ | | ០,០៣ | |
| ០៨ | ទំនាក់ទំនងសភានិងអធិការកិច្ច | ៦៥០ | ៦៥០ | | ០,០០ | ៧៥០ | ៧៥០ | | ០,០១ | |
| ០៩ | ការបរទេស | ៣៥.០០០ | ៣៥.០០០ | | ០,២៩ | ៣៧.៥០០ | ៣៧.៥០០ | | ០,២៩ | |
| ១០ | សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១៥.៦២៧ | ១២.៨៥០ | ១.៩២៧ | ០,១២ | ១៥.៥៥០ | ១២.៩៣០ | ១.៩២០ | ០,១១ | |
| ១៤ | ផែនការ | ២.០៣៥ | ៩៦០ | ១.១៧៥ | ០,០២ | ៣.០០០ | ១.២៧០ | ១.៧៣០ | ០,០២ | |
| ២៦ | យុត្តិធម៌ | ៥.៧២៣ | ៣.១៥០ | ២.៥៧៣ | ០,០៥ | ៧.៣០០ | ៤.០៥០ | ៣.២៥០ | ០,០៥ | |
| ២៦ ១ | យុត្តិធម៌ | ២.០០០ | ២.០០០ | | ០,០២ | ២.៥០០ | ២៥០០ | | ០,០២ | |
| ២៦ ២ | តុលាការកំពូល | ៣.១៧៣ | ៦០០ | ២.៥៧៣ | ០,០៣ | ៤.០០០ | ៦០០ | ៣.២៥០ | ០,០៣ | |
| ២៦ ៣ | សាលាឧទ្ធរណ៍ | ៥៥០ | ៥៥០ | | ០,០០ | ៨០០ | ៨៥០ | | ០,០១ | |
| ៣០ | គ.ជ.ប | | | | ០,០០ | ២.៨០០ | ២.៨០០ | | ០,០២ | |
| | II- ការពារជាតិនិងសន្តិសុខ | ៥៥៥.០០០ | ៥៥៥.០០០ | | ៣,៧៥ | ៥៧០.៥៥០ | ៥៧០.៧៥០ | | ៣,៥០ | |
| ០៦ | ការពារជាតិ | ៣៣០.០០០ | ៣៣០.០០០ | | ២,៧២ | ៣៣៦.២៥០ | ៣៣៦.២៥០ | | ២,៥០ | |
| ០៧ ១ | មហាផ្ទៃ "សន្តិសុខ" | ១២៥.០០០ | ១២៥.០០០ | | ១,០៣ | ១៣៥.៥០០ | ១៣៥.៥០០ | | ១.០០ | |
| | III-រដ្ឋបាលសង្គមកិច្ច | ២៦៩.៩៩៩ | ៩៦.៤៤០ | ១៦២.៩៩៩ | ២,៣៩ | ៣៥៦.៥២០ | ១៣៥.៦០០ | ២៥៧.៥២០ | ២,៩៩ | |
| ១១ | ពត៌មាន | ៤.៩៨១ | ៣.០២០ | ១.៩៦១ | ០,០៤ | ៥.១០០ | ៣.១០០ | ២.០០០ | ០,០៤ | |
| ១២ | សុខាភិបាល | ៨០.១១៦ | ៥៥.៤០០ | ២៥.៧១៦ | ០,៦៦ | ១២១.០០០ | ៨១.០០០ | ៤០.០០០ | ០,៩០ | |
| ១៦ | អប់រំយុវជននិងកីឡា | ១២៤.៧៣៧ | ៣២.៩៥០ | ៩១.៩៩៧ | ១,០៣ | ១៧២.២០០ | ៤៥.៧០០ | ១២៦.៥០០ | ១,២៩ | |
| ១៦ ១ | អប់រំ | ១១២.៩៩៧ | ២១.០០០ | ៩១.៩៩៧ | ០,៩៣ | ១៥០.៥០០ | ២៥.៧០០ | ១២៦.៥០០ | ១,១២ | |
| ១៦ ២ | ឧត្តមសិក្សា | ៩.៣៧០ | ៩.៣៧០ | | ០,០៧ | ១៥.០០០ | ១២.០០០ | | ០,១០ | |
| ១៦ ៣ | យុវជន និងកីឡា | ៣.៥៧០ | ៣.៥៧០ | | ០,០៣ | ៧.៧០០ | ៧.៧០០ | | ០,០៦ | |
| ១៨ | វប្បធម៌ និងវិចិត្រសិល្បៈ | ៤.៧១០ | ២.៥០០ | ២.២១០ | ០,០៤ | ៦.០០០ | ៣.២០០ | ២.៨០០ | ០,០៤ | |
| ១៩ | បរិស្ថាន | ១.៥២១ | ១.១៥០ | ៥៧១ | ០,០២ | ៣.២០០ | ១.៥០០ | ១.៣០០ | ០,០២ | |
| ២១ | សង្គមកិច្ចការងារបណ្តុះបណ្តាល | ២៣.៧០៩ | ១.៦១៥ | ២២.០៩៤ | ០,២០ | ២៦.៥០០ | ១.៥០០ | ២៥.០០០ | ០,២០ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ២៣ | សហការ និងកិច្ច ការ គាំពារ | ១.៦២៧ | ៧០០ | ៩២៧ | ០,០១ | ២.១៨០ | ១០០០ | ១.១៨០ | ០,០២ | |
| ២៩ | កិច្ចការនារី និង អតីតយុទ្ធជន | ៦៧.៧៩៧ | ៧៧៥ | ៦៧.០២២ | ០,៣៩ | ៥៥.៩៨០ | ១.១០០ | ៥៤.៨៨០ | ០,៥៥ | |
| | IV-វិស័យ សេដ្ឋកិច្ច | ១៣៩.២៩៧ | ១១៥.១៧០ | ២៤១២៧ | ១,១៥ | ១៥៦.៣៨០ | ១២៦.៥៨០ | ២៩.៨០០ | ១,១៦ | |
| ០៥ ៣ | អាកាសចរ ស៊ីវិល | ៣.៦០០ | ៣.៦០០ | | ០,០៣ | ៤.០០០ | ៤.០០០ | ០ | ០,០៣ | |
| ១៣ | ឧស្សាហកម្មរ៉ែ និងថាមពល | ៥.១៧៣ | ២.៧០០ | ២.៤៧៣ | ០,០៤ | ៦.០៨០ | ៣.១៨០ | ២.៩០០ | ០,០៥ | |
| ១៥ | ពាណិជ្ជកម្ម | ៦.៤៣២ | ៤.៧០០ | ១.៧៣២ | ០,០៥ | ៧.០៨០ | ៥.១៨០ | ១.៩០០ | ០,០៥ | |
| ១៧ | កសិកម្មរុក្ខា ប្រមាញ់និង នេសាទ | ២៣.៤៩៧ | ១២.៦៧០ | ១០.៨២៧ | ០,១៩ | ២៥.៤០០ | ១៣.៦០០ | ១១.៨០០ | ០,១៩ | |
| ២០ | អភិវឌ្ឍន៍ ជនបទ | ៣.៤៩២ | ១.៥០០ | ១.៩៩២ | ០,០៣ | ៩.១០០ | ៣.៥០០ | ៥.៦០០ | ០,០៦ | |
| ២២ | ប្រៃសណីយ៍ និងទូរគមនា គមន៍ | ៤០.១៣៧ | ៣៩.១២០ | ១.០១៧ | ០,៣៣ | ៤២.៤០០ | ៤១.៣០០ | ១.១០០ | ០,៣២ | |
| ២៥ | សាធារណការ និង ដឹកជញ្ជូន | ៤៤.១៩៣ | ៣៨.០៧០ | ៦.១២៣ | ០,៣៧ | ៤៧.៣០០ | ៤០.៥០០ | ៦.៨០០ | ០,៣៥ | |
| ២៧ | ទេសចរណ៍ | ៥.១១៣ | ៤.១០០ | ១.០១៣ | ០,០៤ | ៦.០០០ | ៤.៤០០ | ១.៦០០ | ០,០៤ | |
| ២៨ | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ២.៧០០ | ២.៧០០ | | ០,០២ | ៤.០០០ | ៤.០០០ | | ០,០៣ | |
| ២៩ | ធនធានទឹក និងឧតុនិយម | ៤.០១០ | ៤.០១០ | | ០,០៣ | ៤.៤០០ | ៤.៤០០ | | ០,០៤ | |
| | V- ចំណាយ មិនទាន់ បែង ចែក : | ៧០.៤០០ | ៧០.៤០០ | | ០,៥៩ | ៨០.០០០ | ៨០.០០០ | | ០,៥៩ | |
| | ជំពូក ២០ : ការផ្តល់ពិសេសការ ខ្ចីបុរេ | ១២.៤០០ | ១២.៤០០ | | ០,១១ | ១៥.០០០ | ១៥.០០០ | | ០,១១ | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | ជំពូក ៥០ : ចំណាយផ្សេងៗ | ៥០.០០០ | ៥០.០០០ | | ០,៤១ | ៥០.០០០ | ៥០.០០០ | | ០,៣៧ | |
| | ជំពូក ៥១ : ចំណាយឥតគ្រោងទុក | ៥.១០០ | ៥.១០០ | | ០,០៧ | ១៥.០០០ | ១៥.០០០ | | ០,១១ | |

បញ្ជាក់ :

-ពិសោធ ១៩៩៩ - ១២.១៣០

-ពិសោធ ២០០០ - ១៣.៤៥០

★★★

## គំរោងចំណាយថវិកា ឆ្នាំ ២០០០
## របស់មន្ទីរជំនាញជុំវិញខេត្ត ក្រុង

ឯកតា = លានរៀល

| ល.រ | ខេត្ត ក្រុង | សរុបរួម | ហិរញ្ញវត្ថុ | ពត៌មាន | សុខាភិបាល | ឧស្សាហកម្ម | ផែនការ | ពាណិជ្ជកម្ម | អប់រំ | កសិកម្ម |
|---|---|---|---|---|---|---|---|---|---|---|
| ១ | រាជធានីភ្នំពេញ | ២៦.៥១១,០ | ១១០,០ | ៥៧,០ | ២២៥៩,០ | ១៩២,០ | ៤៣,០ | ៥៧,០ | ១១៤០០,០ | ៤៩២,០ |
| ២ | កណ្ដាល | ២៣.៩១៩,០ | ៩៣,០ | ៩២,០ | ៧.០៦៥,០ | ១៩១,០ | ១១៦,០ | ៦៦,០ | ១៣.១៩៣,០ | ៧២៧,០ |
| ៣ | កំពង់ចាម | ៣៣.២៥០,០ | ១២២,០ | ៩៣,០ | ៤៣៥៩,០ | ១៦២,០ | ១៩៩,០ | ៥២,០ | ១៦.៨២៩,០ | ៦៣០,០ |
| ៤ | បាត់ដំបង | ៩១២០,០ | ១០៤,០ | ១៩០,០ | ៣៩៥៧,០ | ២០៤,០ | ៧០,០ | ២០៧,០ | ៩២១៣,០ | ៨៣៣,០ |
| ៥ | ព្រៃវែង | ២០៩៩៧,០ | ១៥៥,០ | ១២៤,០ | ២៩៩២,០ | ១៩៩,០ | ១៣៤,០ | ១០២,០ | ១១២៩១,០ | ៨០១,០ |
| ៦ | សៀមរាប | ១៧១៥៣,០ | ១២៦,០ | ១៣៦,០ | ២៥៩១,០ | ៥៩,០ | ១០៤,០ | ១៣១,០ | ៩៩១៦,០ | ៦១៤,០ |
| ៧ | កំពង់ធំ | ១៥៧៩១,០ | ៩៥,០ | ៧២,០ | ២០២៧,០ | ១០០,០ | ៤៧,០ | ៦១,០ | ៦០៨៧,០ | ៥៥៩,០ |
| ៨ | តាកែវ | ១៥០៩៥,០ | ១១៥,០ | ៥១,០ | ២៧៧៩,០ | ១៣៣,០ | ៩៩,០ | ៧៥,០ | ៩២៣៩,០ | ៧៣៦,០ |
| ៩ | ស្វាយរៀង | ១១៣៣៥,០ | ៧០,០ | ៥៥,០ | ១៥៩៧,០ | ១៦៧,០ | ៩៣,០ | ១៣៩,០ | ៤៣៥៦,០ | ៥០៤,០ |
| ១០ | ពោធិ៍សាត់ | ១១០១៣,០ | ១១១,០ | ១៩០,០ | ១៣២០,០ | ១១៥,០ | ៣០,០ | ៦៥,០ | ៥០៥២,០ | ៥៥៧,០ |
| ១១ | កំពង់ឆ្នាំង | ១០៥២៥,០ | ៤៣,០ | ៦១,០ | ១៥៣៣,០ | ៤៣,០ | ៥៥,០ | ១០២,០ | ៥១៩៦,០ | ៥៩៦,០ |
| ១២ | កំពង់ស្ពឺ | ១៥៥៥៥,០ | ៤៣,០ | ៧២,០ | ១១៣៥,០ | ១០៥,០ | ៧៤,០ | ៩០,០ | ៦១៧៥,០ | ៦២៧,០ |
| ១៣ | កំពត | ១៥៩១២,០ | ៧៥,០ | ៧២,០ | ១៩៥០,០ | ១៥០,០ | ៩៣,០ | ១៣១,០ | ៦០១១,០ | ៥៥៥,០ |
| ១៤ | ក្រុងព្រះសីហនុ | ៥៥៩៧,០ | ៥១,០ | ១៥១,០ | ៧១៣,០ | ៧១,០ | ១១១,០ | ៩៩,០ | ១៩៩០,០ | ៥៥១,០ |
| ១៥ | កោះកុង | ៣១៧២,០ | ៥៦,០ | ៣៤,០ | ៥៧៥,០ | ៩៥,០ | ៥៥,០ | ៥១,០ | ៨៥៥,០ | ៣០៥,០ |
| ១៦ | ព្រះវិហារ | ៥៥៥៣,០ | ៩៧,០ | ៣៦,០ | ៦៩១,០ | ៤០,០ | ៣៥,០ | ៣៥,០ | ១៣៥៧,០ | ២៣៣,០ |
| ១៧ | ក្រចេះ | ៦៦៩៥,០ | ៥២,០ | ៥៥,០ | ១១៧០,០ | ១៥០,០ | ៥២,០ | ៣៩,០ | ៣០៦១,០ | ៣៥៥,០ |
| ១៨ | រតនគិរី | ៣៦៥៦,០ | ៥៥,០ | ៥៥,០ | ៩៩៧,០ | ១៩៥,០ | ៥៥,០ | ៥០,០ | ៤៦០,០ | ៣២៧,០ |
| ១៩ | មណ្ឌលគិរី | ២៥៨៦,០ | ៩៦,០ | ៨៥,០ | ៥០២,០ | | ៨៥,០ | ៩០,០ | ៨៥០,០ | ៣៣៧,០ |
| ២០ | បន្ទាយមានជ័យ | ១៥៥៧០,០ | ៦៣,០ | ៦០,០ | ២៧១៩,០ | ២៥៥,០ | ៩១,០ | ៧១,០ | ៦២៥៩,០ | ៣៥៩,០ |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ២១ | ស្ទឹងត្រែង | ៣៦៥៨.០ | ៥៧.០ | ១២៤.០ | ៧៣៩.០ | ១៨៧.០ | ៩០.០ | ៦៨.០ | ១០៩២.០ | ៣៩៣.០ |
| ២២ | ក្រុងកែប | ២១៥៦.០ | ៩២.០ | ៦៦.០ | ១៥៦.០ | ៣៩.០ | ២៣.០ | ៤៥.០ | ៩៨៩.០ | ២០៨.០ |
| ២៣ | ក្រុងប៉ៃលិន | ៣៩៩៥.០ | ៨៧.០ | ១៣២.០ | ៥០៣.០ | ៩៩.០ | ៦០.០ | ៥២.០ | ៣០៧.០ | ១៩៥.០ |
| ផែនការ ១ឆ្នាំ | | ២៩៩៦២០.០ | ១៩២៩.០ | ៦០០០. | ៥០០០០.០ | ២៥០០.០ | ១៧៣០. | ១៥០០.០ | ១២៦៨០០.០ | ១១៧០០.០ |

★★★

## គំរោងចំណាយថវិកា ឆ្នាំ ២០០០
## របស់មន្ទីរជំនាញជុំវិញខេត្ត ក្រុង

គិតជាលានរៀល

| ល.រ | ខេត្ត ក្រុង | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] | [illegible] |
|---|---|---|---|---|---|---|---|---|---|---|---|
| ១ | រាជធានី ភ្នំពេញ | ៣៥៦.០ | ១០៩.០ | ១៩៧.០ | ៩០៦១.០ | | ៩៥.០ | ៤៩៥២.០ | ១៣២៨.០ | ២៦០.០ | ៥០.០ |
| ២ | កណ្ដាល | ១៦៧.០ | ៧៩.០ | ២៦៩.០ | ១៩៩៩.០ | ៦៤.០ | ៩៩.០ | ៣៩៦៦.០ | ៣៨០.០ | ២៣០.០ | ៧១.០ |
| ៣ | កំពង់ចាម | ១៦១.០ | ១០៨.០ | ៣៩៦.០ | ៩៦៣៩.០ | ៦៣.០ | ៩៦.០ | ៩៥០៧.០ | ២៨៩.០ | ២០៥.០ | ៥១.០ |
| ៤ | បាត់ដំបង | ១៥៦.០ | ៥៩.០ | ២៧៨.០ | ១៧២៨.០ | ៧២.០ | ៨០.០ | ៧៨៥១.០ | ៥១៨.០ | ១៥៦.០ | ៩៥.០ |
| ៥ | ព្រៃវែង | ២២៨.០ | ៧០.០ | ៣៣៣.០ | ៧១៩.០ | ១១០.០ | ៧៥.០ | ២៣២០.០ | ៥៧៩.០ | ១៩៩.០ | ៧៧.០ |
| ៦ | សៀមរាប | ១៩៣.០ | ៥១.០ | ១៩៩.០ | ៨៧៣.០ | ៧៥.០ | ៦៣.០ | ៩៦៩៩.០ | ៣០៨.០ | ១៩៣.០ | ១៩៣.០ |
| ៧ | កំពង់ធំ | ១៣៦.០ | ៩៩.០ | ២៦០.០ | ១១៩៩.០ | ៦៨.០ | ៩៩.០ | ៣៦២១.០ | ២១៦.០ | ១២៧.០ | ៣៥.០ |
| ៨ | តាកែវ | ១៥៦.០ | ៥០.០ | ៣៩៦.០ | ៥០៣.០ | ៥១.០ | ៧១.០ | ៣១១៩.០ | ២២៣.០ | ១៨៩.០ | ៧០.០ |
| ៩ | ស្វាយរៀង | ១២៩.០ | ៥១.០ | ២០៩.០ | ៨១០.០ | ៥០.០ | ៦៣.០ | ១៦៧១.០ | ២១៦.០ | ១៩៣.០ | ៣៧.០ |
| ១០ | ពោធិ៍សាត់ | ១១៩.០ | ៤៥.០ | ១៦៩.០ | ១៣២២.០ | ៦៩.០ | ៦៣.០ | ២២៩៧.០ | ២៣៩.០ | ១៣២.០ | ៥៩.០ |
| ១១ | កំពង់ស្ពឺ | ១២៧.០ | ៥១.០ | ២១១.០ | ៦៥៨.០ | ៥២.០ | ៩២.០ | ២១៩៩. | ២២៣.០ | ១៥៧.០ | ៣០.០ |
| ១២ | កំពង់ឆ្នាំង | ១៦២.០ | ៥៩.០ | ២៤៩.០ | ៨២៨.០ | ៩៨.០ | ៥០.០ | ៥៧៦៥.០ | ២៧១.០ | ១៣៦.០ | ៣២.០ |
| ១៣ | កំពត | ១២៦.០ | ៦០.០ | ២៥០.០ | ១០១៩.០ | ៥៦.០ | ៩២.០ | ៣៦០១.០ | ២៩១.០ | ១៧៩.០ | ៥៧.០ |
| ១៤ | ក្រុងព្រះសីហនុ | ៦២.០ | ៤៥.០ | ២២៣.០ | ៤៥៦.០ | ៣៧.០ | ៣៥.០ | ២៨៩.០ | ៣១៥.០ | ១៥៥.០ | ១១៦.០ |
| ១៥ | កោះកុង | ៩១.០ | ៩៨.០ | ១០៩.០ | ២៥០.០ | ៣៧.០ | ៣៥.០ | ៥២៨.០ | ១៥៩.០ | ១១៥.០ | ៣៥.០ |
| ១៦ | ព្រះវិហារ | ៩៩.០ | ៥៥.០ | ៩៣.០ | ១១៩១.០ | ៩៥.០ | ៣៣.០ | ១២២៥.០ | ១១០.០ | ៩៧.០ | ៦២.០ |
| ១៧ | ក្រចេះ | ៨០.០ | ៩០.០ | ១០៥.០ | ៦២៧.០ | ៣០.០ | ៣១.០ | ៦០៦.០ | ១២៣.០ | ១០៥.០ | ៣០.០ |
| ១៨ | រតនគិរី | ៥៨.០ | ៣៩.០ | ១២១.០ | ៥៦១.០ | ២៣.០ | ៣៦.០ | ១៩១.០ | ១២៥.០ | ៨៥.០ | ២៩.០ |
| ១៩ | មណ្ឌលគិរី | ៥៥.០ | ៩៦.០ | ៦៧.០ | ១៧៩.០ | ២០.០ | ៥៣.០ | ៦២.០ | ៥៧.០ | ១៥១.០ | ៣០.០ |
| ២០ | បន្ទាយមានជ័យ | ៧៨.០ | ៣៥.០ | ២១១.០ | ១១១៣.០ | ៥៥.០ | ៥៦.០ | ៣៨០០.០ | ២១៨.០ | ១៣២.០ | ៣០.០ |
| ២១ | ស្ទឹងត្រែង | ៦១.០ | ៥៨.០ | ១១៩.០ | ៣៧០.០ | ១៨.០ | ៥៥.០ | ១១៩.០ | ១៧១.០ | ៧៥.០ | ៣៩.០ |
| ២២ | ក្រុងកែប | ៩៦.០ | ២៦.០ | ៨១.០ | ៥១៨.០ | ១៨.០ | | ៣១៣.០ | ៥៩.០ | | ៣២.០ |
| ២៣ | ក្រុងប៉ៃលិន | ៥៥.០ | ៨៩.០ | ១៧៩.០ | ១១៩.០ | ៥៦.០ | ៣៥.០ | ១៥៦៩.០ | ៦៧.០ | ៦២.០ | ៥៥.០ |
| | ផែនការ ១ឆ្នាំ | ២៨០០.០ | ១៣០០.០ | ៥៣០០.០ | ២៨០០០.០ | ១១៣៣.០ | ១១៥០.០ | ៥៥៥៥០.០ | ៦៥០០.០ | ៣២៥០.០ | ១២០០.០ |

# ការគ្រប់គ្រងឆ្នាំ ២០០០

ក្រសួង

## ចំណូលថវិកាចរន្តរបស់រដ្ឋ

តារាង១

ឯកតា : លានរៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | អនុខ័ណ្ឌ | ការរាយប្រភេទចំណូល (តាមលេខកូដនាមតិកា) | ការគ្រប់គ្រងឆ្នាំ ១៩៩៩ | | គម្រោងឆ្នាំ ២០០០ | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | ច្បាប់ថវិកាឆ្នាំ | ប៉ាន់ស្មានឆ្នាំ | សរុប | អង្គភាពកណ្តាល | ខេត្ត ក្រុង |
| | | | | | | | | | |

ថ្ងៃទី ខែ ឆ្នាំ ១៩៩

អ្នកធ្វើតារាង

ថ្ងៃទី ខែ ឆ្នាំ ១៩៩៩

បានឃើញ និងឯកភាព

ហត្ថលេខា និងត្រា រដ្ឋមន្ត្រី

★★★

# ការគ្រប់គ្រងឆ្នាំ ២០០០

ខេត្ត-ក្រុង

## ចំណូលថវិកាចរន្តរបស់រដ្ឋ

តារាង១

ឯកតា : លានរៀល

| ជំពូក | ប្រការ | គណនី | អនុគណនី | ការរាយមុខចំណូល (តាមតារាងគណនី) | ការគ្រប់គ្រងឆ្នាំ ១៩៩៩ | | គម្រោងឆ្នាំ ២០០០ |
|---|---|---|---|---|---|---|---|
| | | | | | ផែនការដើមឆ្នាំ | ប៉ាន់ស្មាន | |
| | | | | | | | |

ថ្ងៃទី ខែ ឆ្នាំ ១៩៩

អ្នកធ្វើតារាង

ថ្ងៃទី ខែ ឆ្នាំ ១៩៩៩

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី ខែ ឆ្នាំ ១៩៩៩

ហត្ថលេខា និងត្រា អភិបាលខេត្ត

***

# គំរោងថវិកាឆ្នាំ ២០០០

ក្រសួង

## ការវិនិយោគរួម

តារាង២

| | | ១៩៩៥ ការពិត | ១៩៩៦ ការពិត | % | ១៩៩៧ ការពិត | % | ១៩៩៨ ការពិត | % | ១៩៩៩ ច្បាប់ថវិកា | % | ២០០០ គម្រោង | % |
|---|---|---|---|---|---|---|---|---|---|---|---|---|
| សរុបផលិតផលក្នុងស្រុក (ពាន់លានរៀល) | | ៧៣៦.៧៩ | ៧៩៨.៧៧ | | ៨១៥.៩៩ | | ៩៣៣.៩៧ | | ១១៤០.១៤ | | ១២៩៩.០០ | |
| | %កំណើន ផលិតផលក្នុងស្រុក (ពាន់លានរៀល) %នៃ ផសស | ៧២០០.០០ ១០.២៣ % | ៨២៥០.០០ ៨.៩៧ % | ៧.១៩% ១៥.៦០ | ៩១០០.០០ ៩.៩៧ % | ៣.០២% ១០.៣០ | ១០៧៩០.០០ ៨.៦៩ % | ១៥.៩៥% ១៦.១៣ | ១២១៣០.០០ ៩.៤២ % | ២២.០១ ១៦.៨៩ | ១៣២៥០.០០ ៩.៣៣ % | ៩.០៩% ១០.៩៩ |
| សង្គម.ស | % កំណើន % នៃចំណាយ សរុបក្នុងស្រុក % នៃ ផសស | | | | | | | | | | | |
| ជំពូក ១០ | ចំនួន % កំណើន | | | | | | | | | | | |
| ជំពូក ១១ | ចំនួន % កំណើន | | | | | | | | | | | |
| ជំពូក ៣០ | ចំនួន % កំណើន | | | | | | | | | | | |
| ជំពូក ៣១ | ចំនួន % កំណើន | | | | | | | | | | | |
| ជំពូក ៣២ | ចំនួន % កំណើន | | | | | | | | | | | |
| ជំពូក ... | ....... | | | | | | | | | | | |
| ជំពូក ..... | ....... | | | | | | | | | | | |
| ជំពូក ..... | ........ | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |

★★★

# ការគ្រប់គ្រងឆ្នាំ ២០០០

ក្រសួង

## ចំណាយថវិកាទូទៅរបស់រដ្ឋ

តារាង៣

ឯកតាលានរៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | វាក្យខ័ណ្ឌ | ការបរិយាយមុខចំណាយ (តាមតារាងមាតិកា) | ការគ្រប់គ្រងឆ្នាំ ១៩៩៩ | | គម្រោងឆ្នាំ ២០០០ | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | ច្បាប់ដើមឆ្នាំ | ប៉ាន់ស្មានឆ្នាំ | សរុប | រដ្ឋបាលកណ្ដាល | ខេត្ត ក្រុង |
| | | | | | | | | | |

ថ្ងៃទី ខែ ឆ្នាំ ១៩៩

អ្នកធ្វើតារាង

ថ្ងៃទី ខែ ឆ្នាំ ១៩៩៩

បានឃើញ និងឯកភាព

ហត្ថលេខា និងត្រារដ្ឋមន្ត្រី

★★★

# ការគ្រប់គ្រងឆ្នាំ ២០០០

ខេត្ត-ក្រុង

## ចំណាយថវិកាទុនរបស់រដ្ឋ

តារាង៣

មន្ទីរ .........

ឯកតា : លានរៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | វាក្យខ័ណ្ឌ | ការរាយមុខចំណាយ (តាមតារាងមាតិកា) | ការគ្រប់គ្រងឆ្នាំ ១៩៩៩ | | គម្រោងឆ្នាំ ២០០០ |
|---|---|---|---|---|---|---|---|
| | | | | | ផែនការដើមឆ្នាំ | ប៉ាន់ស្មានឆ្នាំ | |
| | | | | | | | |

ថ្ងៃទី ខែ ឆ្នាំ ១៩៩
អ្នកធ្វើតារាង

ថ្ងៃទី ខែ ឆ្នាំ ១៩៩៩
ហត្ថលេខា និង ត្រាប្រធានមន្ទីរ
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី ខែ ឆ្នាំ ១៩៩៩
ហត្ថលេខា និងត្រា អភិបាលខេត្ត

★★★

# គំរោងថវិកាឆ្នាំ ២០០០

## បញ្ជីសរុប នៃបុគ្គលិក បៀវត្ស និង ប្រាក់បំណាច់

ក្រសួងលេខ ...........

ជំពូកលេខ ...............

តំបន់ ....................

តារាង ៤

| អង្គភាព | បៀវត្ស សរុប | ចំនួនបុគ្គលិក សរុប | ទាយជ្ជទានដែលកត់ត្រាសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ | | | | បុគ្គលិក អណ្តែត | បុគ្គលិក ជាប់កិច្ចសន្យា |
|---|---|---|---|---|---|---|---|---|
| | | | បុគ.អចិត សរុប | ប្រភេទ "ក" | ប្រភេទ "ខ" | ប្រភេទ "គ" | | |
| សរុប | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | |
| នាយកដ្ឋាន អង្គភាព | | | | | | | | |
| នាយកដ្ឋាន អង្គភាព | | | | | | | | |
| នាយកដ្ឋាន អង្គភាព | | | | | | | | |
| នាយកដ្ឋាន អង្គភាព | | | | | | | | |
| នាយកដ្ឋាន អង្គភាព | | | | | | | | |
| នាយកដ្ឋាន អង្គភាព | | | | | | | | |
| នាយកដ្ឋាន អង្គភាព | | | | | | | | |
| នាយកដ្ឋាន អង្គភាព | | | | | | | | |
| នាយកដ្ឋាន អង្គភាព | | | | | | | | |
| នាយកដ្ឋាន អង្គភាព | | | | | | | | |
| នាយកដ្ឋាន អង្គភាព | | | | | | | | |
| នាយកដ្ឋាន អង្គភាព | | | | | | | | |

★★★

## គំរោងថវិកាឆ្នាំ ២០០០

ក្រសួង .............

## ផ្នែកលើមូលដ្ឋានកម្មវិធីសកម្មភាព

ឬ អង្គភាព

តារាង ៥

| កម្មវិធីសកម្មភាព (១) | | ចំនួនមន្ត្រីរាជការ | នាយកដ្ឋានអង្គភាព | សរុប | ជំពូក១០ | ជំពូក១១ | ជំពូក១១ (២) | ជំពូក១១ (៣) | .... | .... | ..... | ... |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | | | | | | | | | | | |
| ក | | | | | | | | | | | | |
| ១ | | | | | | | | | | | | |
| ២ | | | | | | | | | | | | |
| ៣ | | | | | | | | | | | | |
| ៤ | | | | | | | | | | | | |
| ៥ | | | | | | | | | | | | |
| ខ | | | | | | | | | | | | |
| ១ | | | | | | | | | | | | |
| ២ | | | | | | | | | | | | |
| ៣ | | | | | | | | | | | | |
| ៤ | | | | | | | | | | | | |
| ៥ | | | | | | | | | | | | |
| គ | | | | | | | | | | | | |
| ១ | | | | | | | | | | | | |
| ២ | | | | | | | | | | | | |
| ៣ | | | | | | | | | | | | |
| ៤ | | | | | | | | | | | | |
| ៥ | | | | | | | | | | | | |
| ឃ | | | | | | | | | | | | |
| ១ | | | | | | | | | | | | |
| ២ | | | | | | | | | | | | |
| ៣ | | | | | | | | | | | | |
| ៤ | | | | | | | | | | | | |

(១) រៀបរាប់សកម្មភាព (១.២.៣....... ) របស់នាយកដ្ឋាន ឬ អង្គភាព និង បូកសរុបតាមកម្មវិធី( ក ខ គ ) ។

(២) ញែកនូវចំណាយដោយឡែករបស់ផ្នែកដែលមាននៅក្នុងជំពូក១១ ។ សូមរំលឹកថា ចំណាយដោយឡែករបស់ផ្នែក គឺជាចំណាយក្រៅពីចំណាយដំណើរការធម្មតាដែល ទាក់ទងទៅនឹងបេសកកម្មពិសេសរបស់ក្រសួង ដូចជាសំភារៈគរុកោសល្យសំរាប់អប់រំ ទិញថ្នាំពេទ្យ និងប្រដាប់ប្រដាក់សំរាប់សុខាភិបាល ថែទាំមណ្ឌីបដ្ឋានបុរាណវត្ថុសំរាប់វប្បធម៌ ...... ) ។

(៣) សំរាប់តែកម្មវិធីរបស់ក្រសួង ។

## គំរោងថវិកាឆ្នាំ ២០០០

## ការវិវត្តន៍នៃកម្មវិធី

ក្រសួង .............

ឬ អង្គភាព .............

តារាង ៦

| កម្មវិធីសកម្មភាព (*) | | ចំនួនមន្ត្រីរាជការ | នាយកដ្ឋានអង្គភាព | ១៩៩៩ | ២០០០ | ការប្រែប្រួលឆ្នាំ ២០០០/១៩៩៩ | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | | | | | លំអៀង | % | កំណែទម្រង់ | បញ្ចប់កម្មវិធី | កម្មវិធីថ្មី |
| ក | | | | | | | | | | |
| ១ | | | | | | | | | | |
| ២ | | | | | | | | | | |
| ៣ | | | | | | | | | | |
| ៤ | | | | | | | | | | |
| ៥ | | | | | | | | | | |
| ខ | | | | | | | | | | |
| ១ | | | | | | | | | | |
| ២ | | | | | | | | | | |
| ៣ | | | | | | | | | | |
| ៤ | | | | | | | | | | |
| ៥ | | | | | | | | | | |
| គ | | | | | | | | | | |
| ១ | | | | | | | | | | |
| ២ | | | | | | | | | | |
| ៣ | | | | | | | | | | |
| ៤ | | | | | | | | | | |
| ៥ | | | | | | | | | | |
| ឃ | | | | | | | | | | |
| ១ | | | | | | | | | | |
| ២ | | | | | | | | | | |
| ៣ | | | | | | | | | | |
| ៤ | | | | | | | | | | |

(*) តម្រៀបចំណងជើងសកម្មភាព (១.២.៣....... ) របស់នាយកដ្ឋាន ឬ អង្គភាព និងធ្វើការ ប្រមូលសរុបតាមកម្មវិធី ( ក ខ គ ........... ) ។

# គំរោងថវិកាឆ្នាំ ២០០០

ក្រសួង លេខ ............ **ឥណទាន : ជំពូក១១ - ប្រការ០១ - កថាខ័ណ្ឌ០១**

ផ្នែកលេខ .............

ជំពូក .....................

**តារាង ៧**

| ឥណទាន<br>អង្គភាព | សរុប | ឥណទានប្រើប្រាស់ក្នុងរដ្ឋបាល | | | | ឥណទានប្រើប្រាស់ក្នុងមូលដ្ឋាន | | | |
|---|---|---|---|---|---|---|---|---|---|
| | | ០១ ថ្លៃឈ្នួល | ០២ ការរៀបចំ | ០៣ ទឹក | ០៤អគ្គិសនី | ០១ ថ្លៃឈ្នួល | ០២ ការរៀបចំ | ០៣ ទឹក | ០៤អគ្គិសនី |
| សរុប | | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | | |
| នាយកដ្ឋានអង្គភាព | | | | | | | | | |
| នាយកដ្ឋានអង្គភាព | | | | | | | | | |
| នាយកដ្ឋានអង្គភាព | | | | | | | | | |
| នាយកដ្ឋានអង្គភាព | | | | | | | | | |
| នាយកដ្ឋានអង្គភាព | | | | | | | | | |
| នាយកដ្ឋានអង្គភាព | | | | | | | | | |
| នាយកដ្ឋានអង្គភាព | | | | | | | | | |
| នាយកដ្ឋានអង្គភាព | | | | | | | | | |
| នាយកដ្ឋានអង្គភាព | | | | | | | | | |
| នាយកដ្ឋានអង្គភាព | | | | | | | | | |

***

# គំរោងថវិការឆ្នាំ ២០០០

ក្រសួង លេខ ........ **ចលនវត្ថុ - សំភារៈ និង សំភារៈការិយាល័យ**

ផ្នែកលេខ ........ **ជំពូក១១ - មាត្រា០១ - កថាខ័ណ្ឌ០២ និង ០៤**

ក់រន់ ..........

តារាង ៨

| អង្គភាព | សរុប | ចលនវត្ថុ និង សំភារៈ | | ក្រដាសបោះពុម្ពនិងគ្រឿងផ្គត់ផ្គង់ | |
|---|---|---|---|---|---|
| | | ការទិញ | ការថែទាំ | ក្រដាសបោះពុម្ព | សំភារៈការិយាល័យ |
| សរុប | | | | | |
| មន្ទីរកណ្តាល | | | | | |
| នាយកដ្ឋាន/អង្គភាព | | | | | |
| នាយកដ្ឋាន/អង្គភាព | | | | | |
| នាយកដ្ឋាន/អង្គភាព | | | | | |
| នាយកដ្ឋាន/អង្គភាព | | | | | |
| នាយកដ្ឋាន/អង្គភាព | | | | | |
| នាយកដ្ឋាន/អង្គភាព | | | | | |
| នាយកដ្ឋាន/អង្គភាព | | | | | |
| នាយកដ្ឋាន/អង្គភាព | | | | | |
| នាយកដ្ឋាន/អង្គភាព | | | | | |
| នាយកដ្ឋាន/អង្គភាព | | | | | |

★★★

# គំរោងថវិកា ឆ្នាំ ២០០០

ក្រសួង ........ **សំរាប់និញ្ញត្រូវឥន្ធនៈប្រើប្រាស់រថយន្ត ម៉ូតូ និង ម៉ាស៊ីនភ្លើង**

ផ្នែកលេខ ....... **ជំពូក១១ - ប្រការ០១ - កថាខ័ណ្ឌ០៧ ធាតុខ័ណ្ឌ០២**

តំបន់ .......

តារាង ៩

| លេរ | មធ្យោបាយ | | សរុប | ប្រេងឥន្ធនៈ | | ប្រេងរំអិល MO | | |
|---|---|---|---|---|---|---|---|---|
| | ប្រភេទមធ្យោបាយ | សរុប | ទឹកប្រាក់ | EA | DO | ម៉ាស៊ីនសាំង | ម៉ាស៊ីនម៉ាស៊ូត | សរុប |
| ១ | សរុប | | | | | | | |
| ២ | | | | | | | | |
| ៣ | | | | | | | | |
| ៤ | | | | | | | | |
| ៥ | | | | | | | | |
| ៦ | | | | | | | | |
| ៧ | | | | | | | | |
| ៨ | | | | | | | | |
| ៩ | | | | | | | | |
| ១០ | | | | | | | | |
| ១១ | | | | | | | | |
| ១២ | | | | | | | | |
| ១៣ | | | | | | | | |
| ១៤ | | | | | | | | |
| ១៥ | | | | | | | | |
| ១៦ | | | | | | | | |
| ១៧ | | | | | | | | |

## គំរោងថវិកាឆ្នាំ ២០០០

ក្រសួង .........

## ចំណាយធូខាត់ សោហ៊ុយ : ជំពូក១១ - ប្រការ០២

ផ្នែកលេខ .........

តំបន់ ...............

តារាង១០

| ប្រភេទបេសកកម្ម | សរុប | បេសកកម្មនៅក្នុងប្រទេស | | | បេសកកម្មអន្តរមណ្ឌល | | | បេសកកម្មក្រៅប្រទេស | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| អង្គភាព | | សោ. ដឹកជញ្ជូន | សោ. បេសកកម្ម | សោ. ស្នាក់នៅ | សោ. ដឹកជញ្ជូន | សោ. បេសកកម្ម | សោ. ស្នាក់នៅ | សោ. ដឹកជញ្ជូន | សោ. បេសកកម្ម | សោ. ស្នាក់នៅ | សោ. ផ្សេងៗ |
| សរុប | | | | | | | | | | | |
| ខុទ្ទកាល័យ | | | | | | | | | | | |
| នាយកដ្ឋាន<br>អង្គភាព | | | | | | | | | | | |
| នាយកដ្ឋាន<br>អង្គភាព | | | | | | | | | | | |
| នាយកដ្ឋាន<br>អង្គភាព | | | | | | | | | | | |
| នាយកដ្ឋាន<br>អង្គភាព | | | | | | | | | | | |
| នាយកដ្ឋាន<br>អង្គភាព | | | | | | | | | | | |
| នាយកដ្ឋាន<br>អង្គភាព | | | | | | | | | | | |
| នាយកដ្ឋាន<br>អង្គភាព | | | | | | | | | | | |
| នាយកដ្ឋាន<br>អង្គភាព | | | | | | | | | | | |
| នាយកដ្ឋាន<br>អង្គភាព | | | | | | | | | | | |
| នាយកដ្ឋាន<br>អង្គភាព | | | | | | | | | | | |
| នាយកដ្ឋាន<br>អង្គភាព | | | | | | | | | | | |
| នាយកដ្ឋាន<br>អង្គភាព | | | | | | | | | | | |
| | | | | | | | | | | | |

★★★

## ២-នីតិការរដ្ឋមន្ត្រីក្រសួង ឧស្សាហកម្មរ៉ែ និងថាមពល

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៩

### ប្រកាស

### ប្រកាសលេខ ៦៥៨ ឧក-ប្រក

### រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល ។

-បានឃើញលិខិតលេខ ២១៥៦/៩៧ ក.អ.ក ចុះថ្ងៃទី ២២-៧-៩៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-បានឃើញលិខិតលេខ ៦២៨ ប.ស្ថ ចុះថ្ងៃទី ០៧-៥-៩៩ របស់ក្រសួងបរិស្ថាន

-បានឃើញលិខិតលេខ ៣៣៨៦ ល.អ.ស ចុះថ្ងៃទី ០៩-១២-៩៨ របស់សាលាក្រុងភ្នំពេញ ស្តីពីការអនុញ្ញាតអោយសាងសង់អគារកាត់ដេរ ។

-យោងពាក្យស្នើរបស់ក្រុមហ៊ុន អូសេអង់ ហ្គាមិន ចុះថ្ងៃទី ៣០-៥-១៩៩៩

### សំរេច

**ប្រការ ១ :** អនុញ្ញាតអោយក្រុមហ៊ុន អូសេអង់ ហ្គាមិន (OCEAN GARMENT Co.LTD) តំណាងដោយលោក ABDUL MANNAN សញ្ជាតិ បង់ក្លាដេស អាយុ ៥៧ ឆ្នាំ ភេទប្រុស អាស័យដ្ឋាន No.13, Street 87 , gulshan-2 Dhaka , BANGLADESH, កាន់លិខិតឆ្លងដែនលេខ O 0353315 ចុះថ្ងៃទី០៤ - ០២ - ៩៩ បង្កើត " រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ " ដែលមានឈ្មោះថា " រោងចក្រកាត់ដេរ អូសេអង់ ហ្គាមិន " មានទីតាំងស្ថិតនៅ ដីឡូត៍លេខ ៣១១ អា ផ្លូវលេខ ២៧១ សង្កាត់ទំនប់ទឹក ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

**ប្រការ ២ :** ការសាងសង់ និងរៀបចំគ្រឿងចក្រ ក្រុមហ៊ុន ត្រូវធ្វើទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និងថាមពល អោយបានសំរេចក្នុងរយះពេល ០៣ ខែ ដោយរាប់បញ្ចូលទាំងរយះពេលដំណើរការសាកល្បងផង ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និង គុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ "កាត់ដេរ-សំលៀកបំពាក់" ទៅតាមគំរូ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុន ត្រូវស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវ លើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរ មានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលមានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន អ្នកគ្រប់គ្រង ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអនុភាពគតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ស៊ុយ សែម

***

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ កក្កដា ឆ្នាំ ១៩៩៩

### ប្រកាសលេខ ០៦២៦/៩៩ ពម.ប្រក

### ស្តីពីការតែងតាំងមន្ត្រីរាជការ នៅមន្ទីរពត៌មាន ខេត្តបន្ទាយមានជ័យ

***

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពត៌មាន

-យោងលិខិតលេខ ៣៥៧ ប.ជ ចុះថ្ងៃទី ១១-៥-៩៩ របស់សាលាខេត្តបន្ទាយមានជ័យ ស្តីពីសំណើតែងតាំងថ្នាក់ដឹកនាំមន្ទីរពត៌មានខេត្តបន្ទាយមានជ័យ

-ពិនិត្យលើលក្ខណៈសម្បត្តិ និងសមត្ថភាពមន្ត្រីរាជការ ។

**សំរេច**

**ប្រការ ១** : តែងតាំង ១-លោក ម៉ិត សាម៉ន បច្ចុប្បន្នអនុប្រធានមន្ទីរពត៌មាន ជាប្រធានមន្ទីរពត៌មាន ខេត្តបន្ទាយមានជ័យ

២- លោក អ៊ុក សឿន បច្ចុប្បន្ន ជាប្រធានការិយាល័យវិទ្យុ និងទូរទស្សន៍ ជាអនុប្រធានមន្ទីរពត៌មាន ខេត្តបន្ទាយមានជ័យ

**ប្រការ ២** : ឯកឧត្តមអគ្គនាយករដ្ឋបាល-ហិរញ្ញវត្ថុ លោកនាយកខុទ្ទកាល័យ លោកអគ្គនាយក នៃអគ្គនាយកដ្ឋានចំណុះ លោកប្រធាននាយកដ្ឋានបុគ្គលិក លោកប្រធាននាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញកិច្ច លោកប្រធានមន្ទីរពត៌មានគ្រប់ខេត្ត-ក្រុង និងសាមីជន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
**លី ឡាយស្រេង**

★★★